# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែកញ្ញា លេខ ៩

ព.ស. ២៤៩៧ — គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ


— វិធីអប់រំចិត្ត .................... លោក ស៊ុន- ហ៊ាន ....... ៦៤៣

— ពុទ្ធបរិស័ទ គឺអ្នកណា .......... ឃុនបណ្ណានុរ័ក្ស ប៊ូ- ប៉ូ .... ៦៥៦

— បញ្ញាសជាតក ភាគទី ២ (តមក) . ... បណ្ឌិតមហា ឈឹម- ស៊ុម .... ៦៦៥


*ផ្នែកអក្សរសាស្ត្រ*


— រឿងសៅរ៍សោយ (តមក) ........ ព្រះមហាឧត្តមវិជ្ជា ប៊ុង- ប៉ម .. ៦៧៧

— រឿងសាមកុក (តមក) ............ ឧកញ៉ា នូ- កន ......... ៦៨៤

— ទាលៈនឹងទមយន្តី (តមក) ........ អ្នកស្រី ស្រ៊ុន –សារីយ៉ាន់ .... ៦៩៦

— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) .... លោក ផេង -ជ្រីវ ........ ៧០៤


*កំណត់ទីនប្រវត្តិការណ៍*


— ពិធីឈាបនកិច្ចសព ព្រះអភយកិរក្ខិត
អ៊ុយ- ផាង ............... ឧកញ៉ា មួង- ឃួន ....... ៧១២



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page


— Le perfectionnement moral. · *M. SIN-HEAN* . . . . . . . . 643

— Les Bouddhistes . . . . . . . *M. BOU-PO* . . . . . . . . . . 656

— Pannasajataka vol-II (suite) . *M. CHHIM-SOUM* . . . . . . 665


PARTIE LITTERAIRE:


— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Vén. PEUNG-PAM* . . . . . . 677

— Histoire de Samkok (suite) . . *Oknha NOU-KAN* . . . . . . . 684

— Nala et Damayanti (suite) . . . *Mme SRIN-SARIS-YANN* . . . 696

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . . . . 704


NOTES ET CHRONIQUES:


— L'incinération du Vén. Brah Amarabhirakkhita UY-PANG . *M. MUONG-KHUON* . . . . . 712


Prix d'abonnement annuel (comprenant 12 numéros) 200$00

វិធីអប់រំចិត្ត

# ស៊ិន-ហាំង ស្មៀននៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

## ១ — ចិត្តគឺអ្វី?

ចិត្តគឺជាធម្មជាតគ្មានរូបដែលជាស្ដេចគ្រប់គ្រងនគរកាយ ។ ចិត្តនេះគេមិនអាចមើលឃើញដោយមំសចក្ខុបានទេ ព្រោះជានាមធម៌, តាមពិត អ្នកដែលមិនដឹងចិត្តថាគឺអ្វី តែងមិនឃើញចិត្តទេ, តែកាលបើដឹងថាចិត្តគឺអ្វី តែងឃើញចិត្តបានតាមកម្លាំងនៃសេចក្ដីដឹងនោះ ។

គេច្រើនចូលចិត្តថា វិញ្ញាណ, មនោ, ចិត្ត ទាំង ៣ នេះដូចគ្នា, ព្រោះហេតុនោះ គេទើបកំណត់វិញ្ញាណជាចិត្ត ចិត្តជាវិញ្ញាណខ្លះ, មនោជាចិត្ត ចិត្តជាមនោខ្លះ, ច្រឡូកច្រឡំគ្នាអស់ទៅ ទាំងនេះឯងព្រោះតែមិនស្គាល់ចិត្តថាជាអ្វី ។ ដែលពិតនោះ វិញ្ញាណ, មនោ, ចិត្តនេះ មានមុខការផ្សេងៗ គ្នា តែជាប់ទាក់ទងគ្នា ។

វិញ្ញាណគឺការដឹងច្បាស់ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ហើយវិញ្ញាណនេះជាផ្លូវដែលជាប់តដល់ចិត្ត ហេតុនោះ វិញ្ញាណទុកដូចជាអ្នកបញ្ជូន, មនោទុកដូចជាអ្នកទទួល, ចិត្តទុកដូចជាអ្នកដឹង ។ ចិត្តដែលមានស្រឡាញ់មានស្អប់ជាដើម ព្រោះមានគ្រឿងផ្សំគឺអារម្មណ៍

ហើយនឹងគ្រឿងទទួលគឺកិលេស ។ អារម្មណ៍នឹងកិលេសផ្សំគ្នាកាលណា ក៏ធ្វើចិត្តឲ្យវិបរិត ដូចវិទ្យុកំចាយសម្លេង ត្រូវមានគ្រឿងបញ្ជូននឹងគ្រឿងទទួលសម្លេងទើបប្រាកដបាន ពុំនោះទេដូចអគ្គិសនីដែលឲ្យកើតប្រយោជន៍ជាច្រើន មានឲ្យកើតពន្លឺជាដើម ក៏ព្រោះមានគ្រឿងផ្សំព្រមទាំងខ្សែ ប្រដាប់បើកបិទ នឹងអំពូលដូចម្តេចមិញ, វិញ្ញាណ, មនោ ចិត្ត ក៏មានមុខការជាប់ទាក់ទងគ្នាដូច្នោះដែរ ។ ចិត្តដែលមានអារម្មណ៍ចូលមកផ្សំព្រោះអំណាចកិលេស ដែលមានឫសគល់មកអំពីរាគៈ ឬ លោភៈ ទោសៈ មោហៈ ទើបមានសេចក្តីស្រឡាញ់សេចក្តីស្អប់; ចិត្តដូច្នេះ នៅក្រោមអំណាចកិលេស ។ សេចក្តីជាប់ចំពាក់ទាំងឡាយក្នុងលោក ដែលកើតឡើងហើយក្នុងអតីតក្តី ក្នុងបច្ចុប្បន្នក្តី ក្នុងអនាគតក្តី តែងកើតមានឡើង ព្រោះចិត្តនៅក្រោមអំណាចកិលេសជាមូលហេតុ ។ កាលណាចិត្តមិនមានគ្រឿងផ្សំគឺអារម្មណ៍ នឹងគ្រឿងទទួលគឺកិលេសទេ កាលនោះចិត្តក៏មានអំណាចលើកិលេស គឺនៅក្នុងលោក សូម្បីលោកនឹងជាប់ចំពាក់ដូចម្តេច ក៏មិនអាចធ្វើឲ្យចិត្តញាប់ញ័របាន ។ ព្រោះហេតុនោះ ក្នុងផ្លូវព្រះពុទ្ធសាសនាទើបលើកការអប់រំចិត្តថាជាកិច្ចសំខាន់បំផុត ។ រឿងរ៉ាវនឹង វត្ថុស្ថានទាំងឡាយដែលប្រាកដនៅក្នុងលោក សុទ្ធតែជាអាការសំដែងចេញរបស់ចិត្តទាំងអស់ ។ វត្ថុគ្រប់យ៉ាងទើបធ្លាក់ក្នុងអំណាចរបស់ចិត្ត មានតែចិត្តប៉ុណ្ណោះទេដែល

អាចធ្វើលោកឲ្យញាប់ញ័រ ឬធ្វើលោកឲ្យស្ងប់បាន ព្រោះហេតុដូច្នោះ ទើបគួរអប់រំចិត្ត ។

## ២— លក្ខណៈរបស់ចិត្ត

ចិត្តជាធម្មជាតិវិចិត្រក្រៃពេក ដោយសារអារម្មណ៍ចូលមកផ្សំ ដូចពណ៌ដែលជ្រលក់សំពត់ កាលបើពណ៌បែបណាជ្រលក់សំពត់ សម្បីសំពត់នោះមានពណ៌ស ក៏ត្រូវផ្លាស់ទៅតាមពណ៌ដែលជ្រលក់នោះ សំពត់ទើបមានពណ៌ផ្សេងៗ ដូចម្ដេចមិញ ចិត្តក៏ដូច្នោះដែរ ។ មនុស្សម្នាក់ៗមានចិត្តតែ ១ ដួងទេ តែដែលមានច្រើនដួង ព្រោះអារម្មណ៍នោះឯងចូលមកលាយ, គឺកាលចិត្តប្រកាន់អារម្មណ៍ណា ក៏ប្រែទៅតាមអារម្មណ៍នោះ, អាការដែលសំដែងចេញក៏រមែងប្រព្រឹត្តទៅតាមអារម្មណ៍នោះ ។

លោកពោលថា ចិត្តនេះជាធម្មជាតបម្រះនទៀល អន្ទះអន្ទែង រក្សាបានដោយក្រ ហាមឃាត់បានដោយក្រ ត្រាច់ទៅក្នុងទីឆ្ងាយ ត្រាច់ទៅតែ ១ ដួង មានកាយជាទីអាស្រ័យ ហេតុនេះ ការកំណត់ដឹងលក្ខណ របស់ចិត្ត ក៏គួរនឹងកំណត់ដឹងដោយន័យនេះ ។

តាមប្រក្រតី ចិត្តនេះកាលបើត្រូវព្រាត់ប្រាសចាកអារម្មណ៍ដែលធ្លាប់សេពគប់មកហើយ ក៏សំដែងអាការបម្រះនទៀល ដូចត្រីដែលគេលើកចេញពីទឹកបោះទៅលើគោក, ជាធម្មជាតអន្ទះអន្ទែង ដោយសំដែងអាការឲ្យប្រាកដដូចពានរក្នុងព្រៃ ឬដូចទង់ដែលនៅលើសសរ

កាលខ្យល់បក់ក៏ត្រឡប់ទៅត្រឡប់មក, ជាធម្មជាតរក្សាបានដោយកម្រ គេក៏ដឹងបានដោយអាការដែលសំដែងចេញ ដូចគោដែលនៅជិតស្រែ មានសំទូង គេកម្រនឹងរក្សាកុំឲ្យស៊ីសំទូងក្នុងស្រែនោះបាន, ជាធម្មជាត ហាមឃាត់បានដោយកម្រ ដោយមានអាការដូចក្មេងដែលកំពុងរពឹស កម្រនឹងហាមឃាត់មិនឲ្យរពឹសបាន, ត្រាច់ទៅក្នុងទីឆ្ងាយបំពោះតែ ១ ដួងគឺត្រាច់ស្វែងរកអារម្មណ៍ ឬរឿងរ៉ាវដែលធ្លាប់ដឹងធ្លាប់ឃើញមិនឈប់ឈរ ស្ថានទីណាដែលធ្លាប់ទៅហើយ សូម្បីត្រឡប់មកយូរ ក៏ត្រាច់ទៅក្នុងស្ថានទីនោះបាន កាយនៅទីនេះទេតែចិត្តអាចត្រាច់ទៅពេញលោក បើនឹងកប់រយៈផ្លូវដែលចិត្តត្រាច់ទៅមួយថ្ងៃ ៗ ក៏ហួសប្រមាណ ដែលនឹងកប់បាន បំពោះកាយត្រាច់ទៅមិនបានត្រឹមណា ព្រោះត្រូវហត់នឿយ តែចិត្តមិនមែនដូចកាយទេ ទីណាកាយត្រាច់ទៅមិនបាន ចិត្តត្រាច់ទៅបាន សូម្បីមានគ្រឿងកំបាំងក៏លេចរូបទៅបាន ទីដែលគេហាមក៏បំពានចូលទៅ ព្រោះហេតុអ្វី? ព្រោះអារម្មណ៍ដែលចូលមកផ្សំចិត្តមានច្រើនយ៉ាង ចិត្តប្រកាន់អារម្មណ៍នេះហើយ បណ្ដាយទៅប្រកាន់អារម្មណ៍ឯណោះទៀត វិលទៅវិលមករកទីបំផុតគ្មាន ទើបឈ្មោះថាត្រាច់ទៅក្នុងទីឆ្ងាយ ហើយត្រាច់ទៅតែ ១ ដួង ។

កាយយើងនេះ បើមិនមានចិត្ត ក៏មានអាការដូចភាពយន្តដែលខ្វះមនុស្សទាញ កាលបើមានចិត្តចូលផែបអាស្រ័យ ក៏មានអាការដូច

កាពយន្តដែលមានមនុស្សភាញ, កាពយន្តនឹងសំដែងអាការលោតពំ ផ្លាស់ប្តូរទៅយ៉ាងណា ក៏ព្រោះមនុស្សទាញ, កាយសំដែងអាការឲ្យប្រាកដយ៉ាងណាបានក៏ព្រោះចិត្តជាអ្នកបង្គាប់ការ ឬនឹងប្រៀបកាយដូចផ្ទះ ចិត្តដូចអ្នកនៅអាស្រ័យ ផ្ទះនោះបើម្ចាស់អ្នកនៅអាស្រ័យជាមនុស្សមានកិរិយាមារយាទល្អ ក៏ជាផ្ទះល្អ មានគ្រឿងប្រដាប់វិចិត្រល្អ តាមកម្លាំងរបស់ម្ចាស់ផ្ទះ ជាទីគួរមើលគួរសរសើរជាបសាទនីយស្ថាន ឲ្យកើតសេចក្តីជ្រះថ្លាដល់អ្នកបានឃើញ ដូចព្រះសុគន្ធកុដី ទីគង់នៅរបស់ព្រះពុទ្ធ ឬប្រាសាទរាជវាំងរបស់ព្រះមហាក្សត្រជាដើម តែបើម្ចាស់ផ្ទះនោះជាមនុស្សមិនល្អ គឺជាពាលជន ដូចចោរជាដើម ផ្ទះនោះក៏ត្រឡប់ក្លាយទៅជាទីគួរខ្ពើម មិនគួរឲ្យចូលជិតបាន ខនេះមានឧបមាដូចម្តេច កាយនឹងចិត្តក៏ដូច្នោះដែរ ។ កាលចិត្តបានទទួលការអប់រំក្នុងផ្លូវល្អដែលជាប្រយោជន៍ហើយ អាការដែលសំដែងចេញមកតាមផ្លូវកាយផ្លូវវាចាក៏ល្អ តែបើចិត្តខ្វះការអប់រំ ឬ បានអប់រំក្នុងផ្លូវមិនជាល្អ ដែលប្រាសចាកប្រយោជន៍ ប្រាសចាកធម៌ អាការដែលសំដែងចេញមកតាមផ្លូវកាយផ្លូវវាចាក៏មិនល្អ ដោយន័យនេះទើបអាចឃើញបានថា ចិត្តសំខាន់ជាងកាយ ព្រោះហេតុនោះយើងគួរអប់រំចិត្តតាមសមត្ថភាពនឹងឱកាស មិនគួរបណ្តោយចិត្តឲ្យធ្លាក់នៅក្នុងអំណាចកិលេស គួរតាមរក្សាហាមប្រាមការពារកុំឲ្យប្រព្រឹត្តទៅដូច្នោះ, ពេលគួរអត់សង្កត់

ក៏ចូរអត់សង្កត់ ពេលគួរបង្ក្រាប់ក៏ចូរបង្ក្រាប់កុំបណ្ដោយឲ្យចិត្តទៅតាមអំណាចកិលេស ដែលជាហេតុនាំទុក្ខទោសមកឲ្យ, ពេលគួរស្ទួយលើកដំកើង ក៏ចូរស្ទួយលើកដំកើងឲ្យក្លាហានឲ្យត្រេកអររីករាយ កុំធ្វើចិត្តឲ្យរួញរាងោកងក់, ពេលគួរសម្ងំពិនិត្យ ក៏ចូរសម្ងំពិនិត្យចុះ ។

សាធុជនទាំងឡាយ ដែលប្រាកដថាជាអ្នកមានកិត្តិស័ព្ទល្អ មានសុខចំរើនរុងរឿងមិនសាបសូន្យ ក៏ព្រោះបានអប់រំចិត្តរបស់ខ្លួនតាមសមគួរ, ផ្សេងគ្នាខ្លះ តែការអប់រំតិច អប់រំច្រើន អប់រំក្នុងផ្លូវលោក ឬអប់រំក្នុងផ្លូវធម៌ប៉ុណ្ណោះ ។ ចំណែកផលដែលកើតមកអំពីការអប់រំនោះ ក៏ប្រាកដជាអំណោយផលឲ្យតាមកម្លាំងនៃការអប់រំ. កាលអប់រំក្នុងផ្លូវណាត្រឹមណា ក៏រមែងបានផលក្នុងផ្លូវនោះត្រឹមនោះ មិនប្រាសចាកផលឡើយ ។

## ៣ — វិធីអប់រំចិត្ត

ក្នុងខាងដើមនៃការអប់រំចិត្តនេះ ត្រូវស្គាល់ចិត្តព្រមទាំងស្គាល់លក្ខណៈ និងអាការរបស់ចិត្ត សម្រាប់ត្រួតត្រាពិចារណា ដូចមានកញ្ចក់សម្រាប់ឆ្លុះមើលស្រមោលមុខ ព្រោះធម្មតាការអប់រំគ្រប់យ៉ាងត្រូវមានគ្រឿងសម្រាប់ប្រើក្នុងការនោះ ព្រមទាំងសេចក្ដីសំគាល់នៃការអប់រំ, សូម្បីការអប់រំចិត្តក៏ដូច្នោះដែរ គឺត្រូវរៀនឲ្យដឹងរឿងចិត្តល្មមជាគោលការ និងសេចក្ដីសំគាល់នៃការអប់រំចិត្តជាមុន ដើម្បីធ្វើចិត្តឲ្យជាធម្មជាតគួរ

ដល់ការងារដ៏ប្រពៃ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ឲ្យទាល់តែចិត្តស្ងប់ចាក អកុសលធម៌ទាំងឡាយ មានការដឹងហេតុផលជាក់ច្បាស់តាមសេចក្ដីពិត, ចំណែកផលដែលយើងប្រាថ្នាយ៉ាងក្រៃលែង ក៏គឺឲ្យជាចិត្តពេញបរិបូណ៌ ដោយសេចក្ដីសុខៈមែនៗ មិនមានទុក្ខលាយឡំ ។ ការអប់រំចិត្តនេះមិន មែនគ្រាន់តែទំនុកបំរុងដល់ការងារផ្លូវធម៌ប៉ុណ្ណោះទេ ដែលពិតនោះគឺទំនុក បំរុងដល់ការងារចំណែកគតិលោកផង ព្រោះការងារដ៏ប្រពៃទាំងឡាយ ដែលឲ្យសម្រេចប្រយោជន៍ទាំងខ្លួនឯង ទាំងពួកគណៈប្រទេសជាតិ សុទ្ធ តែមានធម៌ដ៏ប្រពៃលាយឡំទាំងអស់ សូម្បីការអប់រំចិត្តក្នុងទីនេះ ក៏គឺ អប់រំចិត្តឲ្យមានធម៌ដ៏ប្រពៃ ដោយលះបង់ធម៌ចំណែកអកុសលដែលមាន ទុក្ខជាផលនោះចេញ ហើយអប់រំបំពេញធម៌ចំណែកកុសលដែលមាន ផលជាសុខឲ្យកើតមានឡើង ក្នុងចិត្តរបស់ខ្លួន ។

គ្រឿងឧបករណ៍ក្នុងការនេះ ក៏មិនត្រូវមានដើមទុនអ្វីប៉ុន្មានទេ គ្រាន់តែព្យាយាមឲ្យមានសតិគ្រប់ឥរិយាបថ ហើយតាំងចិត្តកំណត់ពិចារណាត្រួតត្រាសង្កេតមើលក្នុងការដែលធ្វើ ពាក្យដែលនិយាយ រឿងដែលគិតឲ្យដឹងថាជាសុចរិត ឬទុច្ចរិត; កាលនឹងធ្វើអ្វី និយាយអ្វី គិតអ្វី គួរពិចារណាមើលថា បើយើងនឹងធ្វើយ៉ាងនេះ គិតយ៉ាងនេះទៅ តើជា សុចរិត ឬទុច្ចរិត, កាលដឹងថាជាសុចរិត គប្បីធ្វើ, គប្បីនិយាយ, គប្បីគិត, កាលដឹងថាជាទុច្ចរិត ក៏កុំធ្វើ កុំនិយាយ កុំគិត; សូម្បីធ្វើហើយ

និយាយហើយគិតហើយ ក៏គប្បីពិចារណាដូច្នោះទៀត កាលដឹងថាជាសុចរិត ក៏គប្បីនៅដោយចិត្តប្រាមោជត្រេកអរ សិក្សាប្រតិបត្តិក្នុងកុសលធម៌ទាំងយប់ទាំងថ្ងៃចុះ កាលដឹងថាជាទុច្ចរិត ក៏គប្បីសំដែងទោសដែលធ្វើល្មើសនោះចេញ ហើយតាំងចិត្តសង្រួមប្រយ័ត្នតទៅ កុំធ្វើថែមទៀត នេះឯងជាកិច្ចខាងដើមនៃការអប់រំចិត្ត ។

កាលបើការធ្វើ ការនិយាយ និងការគិតជាសុចរិតហើយ បើមានបំណងនឹងព្យាយាមបំពេញតទៅ ក៏គួរអប់រំចិត្តរបស់ខ្លួនឲ្យតាំងនៅក្នុងសេចក្ដីស្ងប់, អ្វីជាសត្រូវចំពោះសេចក្ដីស្ងប់ចិត្ត គួរព្យាយាមបង្ក្រាបលះវៀរចេញ ហើយអប់រំបំពេញធម៌ដែលគង្វាលឲ្យកើតសេចក្ដីស្ងប់ចិត្តនោះឲ្យមានឡើង ទ្រាំអត់ធន់ធ្វើចិត្តរបស់ខ្លួនឲ្យធ្ងន់ធ្ង ឱនខ្លួនតែក្នុងធម៌ជាចំណែកកុសល ។ នីវរណៈធម៌ គ្រឿងរាំងរាមិនឲ្យចិត្តបានដល់សេចក្ដីស្ងប់ គឺកាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ច វិចិកិច្ឆា ទាំង ៥ នេះជាសត្រូវដោយត្រង់ចំពោះសេចក្ដីស្ងប់ចិត្ត គួរពិចារណាមើលថា នីវរណៈនោះមានទោសយ៉ាងណា , កាលបើពិចារណាឃើញទោសហើយក៏គួរលះចេញ សូម្បីលះមិនដាច់ស្រឡះទេ ក៏ឈ្មោះថាល្អជាងការបណ្ដោយទៅតាមអំណាចនីវរណៈដែរ, កាលបើនីវរណៈកើតឡើងគ្របសង្កត់ចិត្ត ក៏គួរពិចារណាមើលឲ្យដឹងថានេះជានីវរណៈ ដែលគង្វាលឲ្យកើតសេចក្ដីពេញចិត្តស្រឡាញ់ប្រាថ្នាជាប់ជំពាក់ទៅក្នុងរូប សំឡេង ក្លិន រស សម្ផស្ស

ដែលគួរប្រាថ្នាខ្លះ, កឲ្យកើតអាឃាត បំផ្លាញប្រទូសរ៉ាយគេខ្លះ, កឲ្យកើតសេចក្តីរួញថយ នឹងផុយងោកងក់ខ្លះ, កឲ្យកើតសេចក្តីពយមាយនឹងរសាប់រសល់ខ្លះ, កឲ្យកើតសេចក្តីសង្ស័យមិនដាច់ស្រេចខ្លះ ទាំងនេះឯងសុទ្ធតែជាសត្រូវចំពោះសេចក្តីស្ងប់ចិត្តទាំងអស់ ។ កាលបើដូច្នេះហើយ គួរធ្វើទុកក្នុងចិត្តដោយឧបាយដែលត្រូវ គឺឲ្យឃើញថាអារម្មណ៍ទាំងឡាយមានរូបសម្លេងជាដើមនោះ ដែលគួរស្រឡាញ់ គួរប្រាថ្នាជទេញជទូចិត្ត កំព្រោះចូលចិត្តថាស្រស់បស់ល្អ ដែលជាសេចក្តីចូលចិត្តខុស គួរគិតឲ្យឃើញថាមិនស្រស់បស់មិនល្អទេ តែដែលឃើញថាស្រស់បស់ថាល្អទៅវិញ កំព្រោះការគាក់តែងបរិហារកាយដែលជាចំណែករូបប៉ុណ្ណោះ បើខ្វះការគាក់តែងជាដើមហើយ ការមិនស្រស់បស់ល្អអាចកើតប្រាកដឡើង ។ កាលឧស្សាហ៍ពិចារណាកំណត់យ៉ាងនេះហើយ ចិត្តក៏នឹងឃ្លាតចាកកាមច្ឆន្ទៈនោះបានតាមសមគួរ ព្រោះហេតុនោះ កាលបើនឹងមើលនឹងស្តាប់ជាដើម ទើបគួរជាអ្នកចេះមើលចេះស្តាប់ តទៅនឹងបានប្រយោជន៍មកពីការមើលការស្តាប់នោះពុំខាន ។ សូម្បីនីវរណៈដទៃៗ កើតឡើងក៏គួរពិចារណាដោយឧបាយនេះដែរ ទាល់តែចិត្តដល់នូវសេចក្តីស្ងប់ពិតប្រាកដ មានអាការស្រដៀងនឹងវង់ភ្លើងដែលនៅក្នុងអំពូល, កាលបើអប់រំចិត្តបានយ៉ាងនេះហើយ ឈ្មោះថាជាអ្នកមានចិត្តនៅលើអំណាចនីវរណៈជាថ្នាក់ទី ២ នៃការអប់

វចិត្ត, តពីនេះទៅត្រូវពិចារណាប្រាជ្ញាសេចក្តីកើតរលត់នៃសង្ខារ ញែកចេញឲ្យឃើញជាភាគជាចំណែកដោយត្រូវដល់វោហារថា ខន្ធ ធាតុ អាយតនៈព្រមទាំងហេតុបច្ច័យ ដកបដល់លះសេចក្តីប្រកាន់ដោយអំណាចតណ្ហា មានៈទិដ្ឋិថា "នុះរបស់អាត្មាអញ នុះជាខ្លួនប្រាណរបស់អាត្មាអញ," ដែលជាមគ្គាឲ្យដល់នូវសេចក្តីបរិសុទ្ធហ្មត់ចត់ផុតចាកទុក្ខទាំងពួង; នេះឯងជាកំពូលបំផុតនៃការអប់រំចិត្ត ។

## ៤ — ផលនៃការអប់រំចិត្ត

ចិត្តនេះ កាលបើគេបានអប់រំល្អហើយ ធ្វើឲ្យស្ងប់បរិសុទ្ធហ្មត់ចត់ហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងសេចក្តីចំរើនយ៉ាងក្រៃលែង អាចនាំសេចក្តីសុខមកឲ្យជានិច្ច ។ សេចក្តីសុខដែលកើតមកអំពីការអប់រំចិត្តឲ្យស្ងប់នឹងបរិសុទ្ធនេះ ជាសេចក្តីសុខយ៉ាងត្រជាក់ត្រជុំ មិនមានសេចក្តីសុខណាៗ ក្នុងលោកស្មើបាន, លោកអ្នកមានប្រាជ្ញាទើបនិយមក្នុងការអប់រំចិត្តពន់ពេក ។

ប្រយោជន៍ដែលកើតអំពីការអប់រំចិត្តនោះ ចែកចេញជា ៣ ជាន់ គឺ ទិដ្ឋធម្មិកត្ថៈ (ប្រយោជន៍ក្នុងបច្ចុប្បន្ន), សម្បរាយិកត្ថៈ (ប្រយោជន៍ក្នុងបរលោក), បរមត្ថៈ (ប្រយោជន៍ឧត្តមគឺព្រះនិព្វាន) ។

ទិដ្ឋធម្មិកត្ថៈ អំណោយផលឲ្យតាំងខ្លួនបានជាគោលចារិកត្រឹមត្រូវក្នុងបច្ចុប្បន្ន ។ ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្ត

ឲ្យមានសេចក្ដីឧស្សាហ៍ព្យាយាមក្នុងករណីយកិច្ចដែលជានាទីរបស់ខ្លួន គឺ ជា៖ បើនៅក្នុងវ័យដែលត្រូវសិក្សា ក៏គួរជ្រើសរើសការសិក្សាដែលជាប្រយោជន៍ លះវៀរការសិក្សាដែលជាទោសចេញ, កាលបើឃើញការសិក្សាដែលជាប្រយោជន៍ហើយ ក៏ចូរព្យាយាមចំពោះការសិក្សានោះទាល់តែសម្រេចផលតាមបំណង កុំនឿយណាយរួញរាឡើយ, កាលបើបានទទួលការងារណា ៗ ដែលគេប្រគល់ឲ្យ ក៏ចូរតាំងចិត្តព្យាយាមធ្វើការងារនោះ ៗ ឲ្យបានសម្រេចផលតាមដែលគេប្រគល់ឲ្យឬគេទុកចិត្ត គួរអប់រំចិត្តឲ្យស្មោះត្រង់ចំពោះខ្លួនឯង ចំពោះអ្នកដទៃ ចំពោះការងារដែលជានាទីរបស់ខ្លួន ចំពោះកាលវេលា ចំពោះសមាគម ឲ្យចិត្តមានសតិសម្បជញ្ញៈ អត់ធន់ ក្លៀវក្លា អាចហាន រីករាយ ទន់ភ្លន់, មានសច្ចកតញ្ញូកតវេទី បដិភាណឈ្លាសវៃដឹងហេតុការណ៍មិនភ្ញាក់ផ្អើល អាចប្រកបករណីយនោះ ៗ ឲ្យសមគួរដល់កាលៈទេសៈ ចេះរក្សាករណីយនោះ ៗ មិនឲ្យសាបសូន្យ ឲ្យមានតែសេចក្ដីចំរើនជាលំដាប់ រហូតដល់ទ្រព្យសម្បត្តិដែលរកបានមកដោយធម៌ប្រពៃ ក៏ចេះរក្សានឹងចាយវាយក្នុងផ្លូវដែលជាប្រយោជន៍ ចេះការពារប្រយោជន៍របស់ទ្រព្យសម្បត្តិទុកឲ្យបាន មិនបណ្ដោយឲ្យប្រាសចាកប្រយោជន៍ ដែលនឹងត្រឡប់ជាទោសដល់ខ្លួន តាំងត្រៈជាមនុស្សមានកល្យាណមិត្ររួមកិច្ចការ ឬប្រឹក្សាប្រារព្ធការងារគ្រឿងចិញ្ចឹមជីវិតជាដើម, កាលបើអប់រំចិត្តបានយ៉ាងនេះហើយ គង់នឹងបានទទួលផលដូចពោលមកពុំខាន ។

សម្បរាយិកត្ថៈ អំណោយផលឲ្យបេះធ្វើប្រយោជន៍ដល់ពួកគណៈ ប្រទេសជាតិ ហើយជាគុណសម្បត្តិជាប់នឹងខ្លួន ដូចស្រមោលជាប់តាមប្រាណ សូម្បីនឹងទៅកាន់ទិសណាៗ ក៏រមែងអំណោយផលតាមជូនទៅឧបត្ថម្ភក្នុងទិសនោះៗ មិនឲ្យមានទុក្ខលំបាក ។ ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្តឲ្យមានសទ្ធា គឺជឿក្នុងរបស់ដែលគួរជឿ, ឲ្យមានសីល គឺតាំងចិត្តប្រព្រឹត្តកាយវាចារៀបរយ ប្រាសចាកទោសទាល់តែចិត្តជាប្រក្រតីមិនកំរើកញាប់ញ័រ, ឲ្យមានចាគៈ គឺបេះបង់ចែកលះទាំងខាងក្នុងនឹងខាងក្រៅ ធ្វើចិត្តឲ្យទូលាយមិនចង្អៀត, អ្វីជាសត្រូវរបស់សទ្ធានឹងសីលជាចំណែកខាងក្នុងក៏រមែងលះបាន, អ្វីជាសត្រូវរបស់ការខាងក្រៅក៏រមែងលះបាន, ឲ្យមានបញ្ញាដឹងហេតុផលតាមពិត ក្នុងរបស់ដែលខ្លួនជឿនឹងលះបង់ ។ ការអប់រំចិត្តបានយ៉ាងនេះ រមែងជាហេតុធ្វើចិត្តឲ្យស្គាល់ជាក់លាក់ក្នុងការបំពេញប្រយោជន៍រួមគឺពួកគណៈដែលខ្លួននៅអាស្រ័យ ជាគុណសម្មុទ័យឲ្យជាអ្នកលឿនជាប់គេក្នុងពួកនោះៗ ។

បរមត្ថៈ អំណោយផលឲ្យជាអ្នកមានចិត្តបរិសុទ្ធផុតចាកកិលេសាសវៈ ផុតចាកកងទុក្ខទាំងពួង; ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្តឲ្យមានបញ្ញាជាហេតុដែកទុក្ខ ដែលមានតណ្ហាជាដែនកើត, កាលបើអាចលះតណ្ហាបានដាច់ស្រឡះហើយ កងទុក្ខទាំងពួងក៏រលត់អស់ ដូចភ្លើងដែលអស់ប្រេង រមែងរលត់ទៅដូច្នោះ ។

វិធីអប់រំចិត្តតាមដែលពណ៌នាមកនេះ សូមលោកអ្នកមានប្រាជ្ញាពិចារណាមើលចុះ បើលោកអ្នកនិយមក្នុងការអប់រំចិត្តហើយ តែមិនបានសម្រេចលទ្ធផលដល់ជាន់ខ្ពស់បំផុត បានត្រឹមតែការធ្វើ ការនិយាយ ការគិត ជាសុចរិតប៉ុណ្ណោះ ក៏គប្បីទុកសង្ឃឹមក្នុងចិត្តចុះថា ខ្លួនតិះដៀលខ្លួនឯងមិនបាន, អ្នកដទៃពិចារណាហើយក៏សរសើរ, កិត្តិស័ព្ទខាងល្អរមែងក្រអូបខ្ចរខ្ចាយទៅគ្រប់ទិសានុទិស, មិនជាអ្នកវង្វេងធ្វើកាលកិរិយា, សូម្បីនឹងត្រូវចំលាយខន្ធទៅក៏មានសុគតិជាទីប្រព្រឹត្តទៅក្នុងខាងមុខ, សុទ្ធតែជាផលដែលគួរប្រាថ្នាពិតៗ ទើបជាការសមគួរណាស់តែខំព្យាយាមក្នុងការអប់រំចិត្តនេះ ដើម្បីសម្រេចផលជាសុខក្នុងទីគ្រប់ស្ថាន គ្រប់កាលសម័យ ៗ វិធីអប់រំចិត្តមានន័យដូចពោលមកដូច្នេះឯង ៗ ចប់

ចិត្តសៅហ្មងមកពីមិនប្រឹងអប់រំ
ប្រឹងសន្សំធ្វើតាមសីលនឹងភាវនា,
ចិត្តសៅហ្មងនាំឲ្យរងទុក្ខខ្លោចផ្សា
ក្នុងអនាគតកាលនឹងបច្ចុប្បន្ន ៗ
ចិត្តបរិសុទ្ធផុតមន្ទិលស្រិលស្អាតភ្លឹង
មកអំពីប្រឹងខំបំពាក់មិនស្រាកស្រាន់,
ចិត្តបរិសុទ្ធនាំឲ្យសុខអនេកលន់;
សាធុជនគួរអប់រំចិត្តទៅអើយ!

យ-អ៊ី

ពុទ្ធបរិស័ទគឺអ្នកណា

# ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

## ពាក្យប្រារព្ធ

មនុស្សយើងកើតមកហើយ មិនថាអ្នកមានឬអ្នកក្រ អ្នកខ្ពង់ខ្ពស់ អ្នកថោកទាបទេ សុទ្ធតែស្អប់ខ្ពើមទុក្ខ ចង់បានសុខដូចគ្នាទាំងអស់ គ្មានអ្នកណាចង់បានទុក្ខស្រឡាញ់ទុក្ខសោះ កុំថាដល់ទៅខ្លួនរងទុក្ខ សូម្បីគ្រាន់តែពាក្យថា ទុក្ខ ៗ ក៏មិនចង់ឲ្យឮផង ។ ហេតុនេះ បានជាមនុស្សគ្រប់រូបខំគិតរកឧបាយដើម្បីធ្វើឲ្យខ្លួនផុតពីទុក្ខទោស ឲ្យខ្លួនបានសុខដោយវិធីផ្សេងៗគ្នា អ្នកខ្លះខំធ្វើការងាររកចិញ្ចឹមជីវិតត្រឹមត្រូវតាមផ្លូវលោកផ្លូវធម៌ក៏មាន អ្នកខ្លះធ្វើការងារទុច្ចរិតខុសផ្លូវលោកផ្លូវធម៌ក៏មាន សូម្បីនឿយហត់យ៉ាងណាក៏មិនរួញរា ទាំងនេះ ក៏ព្រោះតែគេចង់ឲ្យខ្លួនបានសុខតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកស្វែងរកសុខនោះ មិនមែនចេះតែបានសុខគ្រប់រូបទេ បើអ្នកណាធ្វើត្រូវតាមផ្លូវឲ្យកើតសុខ អ្នកនោះទើបបានសុខដូចចិត្តប្រាថ្នាទៅ បើអ្នកណាធ្វើខុសផ្លូវឲ្យកើតសុខ អ្នកនោះមិនបានសុខ ត្រឡប់ជាបានទុក្ខផ្ទុយនឹងបំណងខ្លួនទៅវិញ ព្រោះខ្លួនមិនដឹងដើមហេតុដែលឲ្យកើតសុខទុក្ខសោះ ។

តាមពិត សុខទុក្ខជាផលរបស់កម្ម។ ជាហេតុ ។ បើកម្មល្អជាហេតុ តែងបានសុខជាផល, បើកម្មអាក្រក់ជាហេតុ តែងបានទុក្ខជាផល ។ សុខទុក្ខនឹងកើតមានឡើងដោយសារតែខ្លួនឯងជាអ្នកធ្វើ អ្នកណាធ្វើល្អ អ្នកនោះបានសុខ អ្នកណាធ្វើអាក្រក់ អ្នកនោះបានទុក្ខ ។ សុខទុក្ខនេះចែករំលែកឲ្យគ្នាមិនបានទេ បើគ្រាន់តែពន្យល់ប្រាប់ដើមហេតុឲ្យកើតសុខទុក្ខដល់គ្នាបាន ដូចជាប្រាប់គ្នាថា បើអ្នកចង់ដឹងត្រជាក់ ត្រូវអ្នកងូតទឹក បើអ្នកចង់ដឹងក្ដៅ ត្រូវអ្នកហាលថ្ងៃឬអាំងភ្លើងជាដើម ។ ត្រជាក់នឹងក្ដៅមានចំពោះតែខ្លួនអ្នកងូតទឹកឬហាលថ្ងៃប៉ុណ្ណោះ ចំណែកអ្នកប្រាប់មិនត្រជាក់ឬក្ដៅទេ សុខទុក្ខក៏ដូចជាត្រជាក់នឹងក្ដៅនេះដែរ ។

លទ្ធិសាសនាទាំងពួងដែលកើតមានឡើងក្នុងលោក ក៏កើតមកតែអំពីគំនិតរបស់លោកជាសាស្ដានោះៗ គិតចៀសវាងទុក្ខទោសហើយស្វែងរកសុខតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែសាសនាទាំងនោះមានពាក្យប្រៀនប្រដៅផ្សេងៗគ្នា ទៅតាមគំនិតយោបល់សាស្ដានោះៗ ។

ចំពោះព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅអំពីផ្លូវចៀសវាងទុក្ខទោស នឹងផ្លូវធ្វើឲ្យកើតសុខក្នុងលោកនេះនឹងលោកខាងមុខ ដោយបរិយាយដ៏ជ្រាលជ្រៅល្អិតសុខុមណាស់ ដូចកាលព្រះសម្មាសម្ពុទ្ធ បានត្រាស់ដឹងថ្មីៗ ដំបូងបំផុត ទ្រង់ប្រដៅសាវកឲ្យស្គាល់ទុក្ខ, ឲ្យស្គាល់ហេតុកើតទុក្ខ, ឲ្យស្គាល់ទីរលត់ទុក្ខ នឹងឲ្យស្គាល់ផ្លូវប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ, រួមខ្លីថា ព្រះពុទ្ធអង្គទ្រង់ប្រាប់ហេតុឲ្យកើតសុខទុក្ខមុនរឿងផ្សេងៗ ។

ហេតុនេះ មនុស្សគ្រប់រូបទើបត្រូវកាន់សាសនាទុកជាគោលសម្រាប់គ្រប់គ្រងជីវិតរបស់ខ្លួនឲ្យប្រាសចាកទុក្ខ ឲ្យបានសុខស្រួលរាល់ថ្ងៃ ដូចជាកាន់ច្បាប់សម្រាប់ស្រុកទេសដែរ ។ ប៉ុន្តែ អ្នកណាកាន់សាសនាអ្វី . អ្នកនោះត្រូវតែចំគិតដេញដោលរកហេតុផលក្នុងសាសនានោះ ឲ្យឃើញពិតប្រាកដដោយប្រាជ្ញារបស់ខ្លួន កុំចេះតែកាន់សាសនាដោយសារគេបង្ខំ ដោយខ្លាចគេ ឬក៏ដោយអៀនខ្មាសគេ ។

ក្នុងសៀវភៅនេះ ខ្ញុំអធិប្បាយចំពោះតែវិធីប្រតិបត្តិក្នុងព្រះពុទ្ធ-សាសនាមួយប៉ុណ្ណោះ សាសនាឯទៀតលើកទុក ។

សូមលោកអ្នកកាន់ព្រះពុទ្ធសាសនាជួយវិនិច្ឆ័យប្រស្នាទៅនេះផង៖

១ - ព្រះពុទ្ធអង្គជាអ្នកបង្កើតលោកឬ?

២ - ព្រះពុទ្ធអង្គជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលលើសពុទ្ធបញ្ញត្តិឬ?

៣ - ព្រះពុទ្ធអង្គជាអ្នកទទួលទុក្ខទោសជួសពួកសាវ័កឬ?

៤ - ព្រះពុទ្ធអង្គជាអ្នកទទួលពាក្យអង្វរករបន់ស្រន់ របស់ពួកសាវ័កឬ?

៥ - ព្រះពុទ្ធអង្គជាម្ចាស់កម្មផលមែនឬទេ?

ប្រស្នាទាំង ៥ ប្រការនេះ សូមអស់លោកអ្នកមើលសេចក្ដីក្នុងរឿងនេះ កាលបើមើលហើយនឹងបានយល់ច្បាស់ណាស់មិនខាន ។

## អត្ថបទដែលត្រូវពោលក្នុងទីនេះគឺ

១.— ពុទ្ធបរិស័ទ
២.—ករណីយកិច្ចរបស់ពុទ្ធបរិស័ទ
៣.— ដើមកំណើតរបស់ព្រះពុទ្ធជាអ្នកបង្កើតសាសនា
៤.— រូបរាងរបស់ពុទ្ធសាសនា
៥.— វត្ថុបំណងរបស់ពុទ្ធសាសនា
៦.— គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា
៧.— គោលនៃការប្រតិបត្តិធម៌យ៉ាងត្រឹមត្រូវបំផុតក្នុងពុទ្ធសាសនា
៨.— ផលដ៏ប្រសើរបំផុតនៃការប្រតិបត្តិធម៌ក្នុងពុទ្ធសាសនា ។

## ពុទ្ធបរិស័ទ

ពាក្យថា "ពុទ្ធបរិស័ទ" ចែកជា ២ បទ គឺពុទ្ធ ១ បរិស័ទ ១ ។ ពុទ្ធ ជាព្រះនាមនៃព្រះសមណគោតម ដែលជាសាស្តាអ្នកបង្កើតសាសនា(១) ។ បរិស័ទ ជាឈ្មោះពួកជនដែលកាន់សាសនាត្រូវគ្នាដូចជា ពួកពុទ្ធបរិស័ទ, ពួកគ្រិស្តបរិស័ទ, ពួកអិស្លាមបរិស័ទ ជាដើម ។ រួម ពុទ្ធ នឹង បរិស័ទ ភ្ជាប់គ្នាជា ពុទ្ធបរិស័ទ ប្រែថា "បរិស័ទរបស់ព្រះពុទ្ធ" ឬថា "ពួកជនអ្នកកាន់ពុទ្ធសាសនា គឺជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ" ។ ពួកពុទ្ធបរិស័ទទាំងអស់នឹងផ្លាស់ឈ្មោះហៅថា "ពុទ្ធសាសនិកជន" ឬ "ពុទ្ធមាមកៈ" ឬ "ពុទ្ធសាវក" យ៉ាងនេះវិញក៏បាន សំដៅយកពួកជនអ្នកកាន់ពុទ្ធសាសនាដូចគ្នា ។

---

១ មានសេចក្តីពិស្តារក្នុងច្បាប់ពុទ្ធប្រវត្តិឬគម្ពីរបឋមសម្ពោធិ ។

មនុស្សដែលបាននាមថា "ពុទ្ធបរិស័ទ" នោះ គេមិនបានកំណត់ថាជាជាតិអ្វីទេ ។ មិនកំណត់ថាប្រុសឬស្រី ក្មេងឬចាស់ទេ ឲ្យតែអ្នកណាប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធហើយ អ្នកនោះក៏បាននាមថា "ពុទ្ធបរិស័ទ" ដូចគ្នាទាំងអស់ ។ ពុទ្ធបរិស័ទ មាន ២ ពួក គឺគ្រហស្ថ ១ ពួក បព្វជិត ១ ពួក ។

អ្នកដែលមានបំណងចង់តាំងខ្លួនជាពុទ្ធបរិស័ទ ត្រូវតែសិក្សាឲ្យចេះដឹងនូវ ៖

## ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

ខាងពួកគ្រហស្ថ[១] មុនដំបូង ត្រូវតាំងចិត្តជឿកម្មផល និងជឿគុណព្រះរតនត្រ័យ ហើយបន្ទាប់ចាសូមស្មាណ ទោសរួចប្រកាសប្តេជ្ញាខ្លួនថាជាអ្នកគោរពរាប់អានកាន់ពុទ្ធសាសនា នៅទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះភក្ត្រភិក្ខុ ១ រូប ២ រូបឡើងទៅ នៅទីកន្លែងណាក៏បាន ។ លុះធ្វើកិច្ចទាំង ២ យ៉ាងខាងដើមនេះស្រេចហើយ ត្រូវសមាទានសីល ៥ ឬសីល ៨ និងប្រព្រឹត្តតាមធម៌វិន័យសម្រាប់គ្រហស្ថជាច្រើនប្រការទៀត ។ ពុទ្ធបរិស័ទខាងពួកគ្រហស្ថ បើប្រុសហៅ "ឧបាសក," បើស្រីហៅ "ឧបាសិកា" គឺអ្នកតាំងចិត្តយកព្រះរតនត្រ័យជាទីពឹងជាទីរលឹក ។

ករណីយកិច្ចខាងពួកបព្វជិត[២] មុនដំបូង អ្នកដែលចង់បួស ត្រូវ

---

១ ករណីយកិច្ចខាងគ្រហស្ថមានពិស្តារក្នុងច្បាប់គិហិបដិបត្តិ ។ ២ ករណីយកិច្ចខាងអ្នកបួសមានពិស្តារក្នុងបព្វជ្ជាខន្ធក ។

ចូលទៅរកលោកគ្រូអាចារ្យឬព្រះឧបជ្ឈាយ៍ សូមរៀនសូត្រធម៌វិន័យសម្រាប់អ្នកបួសឲ្យបានចេះដឹងល្មមសមគួរហើយ ក៏រកត្រៃចីវរបរិក្ខារសម្រាប់អ្នកបួស, លុះរកបានសព្វគ្រប់ហើយ ចូលទៅសូមបួសក្នុងសំណាក់លោកគ្រូអាចារ្យ. កាលបួសរួចហើយ បើប្រុសហៅថា "សាមណេរ" ឬ "ភិក្ខុ" បើស្រីហៅ "សាមណេរី" ឬ "ភិក្ខុនី" ។

អ្នកដែលបាននាមបញ្ញត្តិថាជា "ពុទ្ធបរិស័ទ" ហើយ គួរណាស់តែចំសិក្សារឿងរ៉ាវនៃព្រះពុទ្ធជាម្ចាស់យ៉ាងល្អិតតទៅទៀត ដើម្បីឲ្យបានយល់ច្បាស់លាស់អំពី៖

## ដើមកំណើតនៃព្រះពុទ្ធជាអ្នកបង្កើតសាសនា

ព្រះពុទ្ធជាបរមគ្រូនៃយើង ជាមនុស្សអស្ចារ្យ ទ្រង់សម្ភពក្នុងសក្យត្រកូល ព្រះជាតិជាក្សត្រ បានឡើងសោយរាជសម្បត្តិក្នុងព្រះជន្ម ១៦ វស្សា ទ្រង់ពិហារណាឃើញសេចក្ដីទុក្ខព្រួយរបស់ព្រះឥន្ទ្រនិងមនុស្សសត្វដទៃ ទើបលះបង់ចោលរាជសម្បត្តិចេញទ្រង់ព្រះផ្នួសក្នុងព្រះជន្ម ២៩ គង់ក្នុងព្រៃចំព្រះរិះរកធម៌ជាគ្រឿងរំលត់ទុក្ខព្រួយអស់វេលា ៦ ឆ្នាំ ទើបទ្រង់បានជាបធម៌ជាគ្រឿងរំលត់ទុក្ខព្រួយនោះ ក្នុងព្រះជន្ម ៣៥ មានព្រះនាមថ្មីថា "ពុទ្ធ" មានព្រះនាមតាមព្រះគោត្រថា "ព្រះពុទ្ធសមណគោតម" ឬ "ព្រះពុទ្ធសក្យមុនីគោតម". ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម ៨០ គត់[១] ។

១ រឿងរ៉ាវនៃព្រះពុទ្ធមានសេចក្ដីពិស្ដារក្នុងច្បាប់ពុទ្ធប្រវត្តិ ឬ ក្នុងគម្ពីរបឋមសម្ពោធិ ។

ពួកពុទ្ធបរិស័ទ កាលបើបានចេះដឹងរឿងរ៉ាវនៃព្រះពុទ្ធហើយត្រូវតែសិក្សាឲ្យយល់ច្បាស់លាស់អំពី ៖

## រូបរាងរបស់ពុទ្ធសាសនា

ពាក្យថា "ពុទ្ធសាសនា" បែកជា ២ បទ គឺពុទ្ធ ១ សាសនា ១ ។ ពុទ្ធ ជាព្រះនាមនៃព្រះបរមសាស្ដាអ្នកផ្ដើមបង្កើតសាសនា ដូចថាមកហើយ ។ សាសនា ប្រែថា "ពាក្យប្រៀនប្រដៅ" រួមចូលគ្នាជា ពុទ្ធសាសនា ប្រែថា "ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ" ។

ពាក្យប្រៀនប្រដៅទាំងអស់ ដែលព្រះបរមសាស្ដាត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទ តាំងពីបានត្រាស់ដឹងជាព្រះពុទ្ធរហូតដល់បរិនិព្វានក្នុងកំឡុង ៤៥ ឆ្នាំ សូម្បីព្រះអង្គសំដែងបែកខ្ញែកទៅជាប៉ុន្មានផ្នែកក៏ដោយ ក៏គង់តែហៅដោយសរុបថា " ពុទ្ធសាសនា " តែម្យ៉ាងប៉ុណ្ណោះ សឹងមានជាប់រហូតមកដល់សព្វថ្ងៃនេះ រាប់ថារូបរាងរបស់ពុទ្ធសាសនា កើតមកបានអាយុ ២៤៩៧ ឆ្នាំហើយ ។

ពួកពុទ្ធបរិស័ទ កាលបើបានស្គាល់រូបរាងរបស់ពុទ្ធសាសនាហើយត្រូវតែត្រិះរិះដេញដោលរកនូវ ៖

## វត្ថុបំណងរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល គោះបីព្រះបរមសាស្ដាត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទដោយព្រះវិនយបិដកក្តី, ព្រះសុត្តន្តបិដកក្តី, ព្រះ

អភិធម្មបិដកក្តី ក៏មានវត្ថុបំណងតែមួយ គឺទ្រង់ដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិឈមមុខទៅរកព្រះនិព្វាន ដែលជាទីរលត់ទុក្ខតែម្យ៉ាងប៉ុណ្ណោះ ។

ប៉ុន្តែ មានន័យជាអនេកប្រការ(១) ដែលព្រះអង្គដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិយកផលប្រយោជន៍នាលោកិយ ដែលជាអ្នកមិនទាន់បានដល់ព្រះនិព្វាន ដូចជាព្រះអង្គត្រាស់ប្រាប់ប្រយោជន៍ ៣ យ៉ាង គឺប្រយោជន៍ក្នុងជាតិនេះ ១ ក្នុងជាតិខាងមុខ ១ ប្រយោជន៍ប្រសើរបំផុតគឺព្រះនិព្វាន ១ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់នូវវត្ថុបំណងរបស់ពុទ្ធសាសនាហើយ ត្រូវតែខំពិចារណាឲ្យល្អិតជ្រាលជ្រៅស្រាវជ្រាវរកនូវ៖

## គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល មានចតុរារិយសច្ច (របស់ពិត ៤ យ៉ាង) ជាកំពូល, ធម៌គ្រប់យ៉ាងសុទ្ធតែសង្គ្រោះរួមចុះក្នុងវង់ចតុរារិយសច្ចទាំងអស់ ។ សេចក្តីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយក៏តែងកើតមានឡើងដើម្បីសេចក្តីចេះដឹងនូវចតុរារិយសច្ចដោយប្រាជ្ញា, ចតុរារិយសច្ចជាកំពូលធម៌, ការចេះដឹងចតុរារិយសច្ច ជាកំពូលនៃព្រហ្មចរិយ,(២) ការប្រតិបត្តិដើម្បីឲ្យត្រាស់ដឹងចតុរារិយសច្ចដោយប្រាជ្ញាជាកំពូលនៃការប្រតិបត្តិទាំងមូល ។

---

១ មានសេចក្តីពិស្តារក្នុងច្បាប់សិក្ខាលោកិទសូត្រលេខ ម. ២១ ។ ២ ការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុត ។

# ចតុរារិយសច្ច

ពាក្យថា "ចតុរារិយសច្ច" ប្រែថា "របស់ពិតដ៏ប្រសើរមាន ៤ យ៉ាង" គឺ

១— ទុក្ខអរិយសច្ច របស់ពិតដ៏ប្រសើរ គឺទុក្ខ.

២— សមុទយអរិយសច្ច របស់ពិតដ៏ប្រសើរ គឺហេតុប្រជុំកើតឡើងនៃទុក្ខ

៣— និរោធអរិយសច្ច របស់ពិតដ៏ប្រសើរ គឺធម៌រលត់ទុក្ខ

៤— មគ្គអរិយសច្ច របស់ពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(មានត)

ពុទ្ធបរិស័ទត្រូវប្រតិបត្តិតាមសាសនា
ទើបហៅថាជាអ្នកកាន់សាសនាពិត
ទាំងត្រូវចាំពុទ្ធប្រវត្តិដោយល្អិតល្អន់
ហើយត្រូវផ្ចិតនិស្ស័យព្រះមកដាក់ខ្លួន ។

យ - អំ

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## សុភមិត្តជាតក ទី ៩

(តមក)

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមានពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម-ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

ព្រះបាទក្រុងសុភមិត្តនោះ លុះទ្រង់ព្រះកន្សែងសោកបោកប្រែះព្រះអង្គយ៉ាងនេះហើយ ក៏មិនអាចទប់ព្រះស្មារតីបានឡើយ ទ្រង់ដួលសន្លប់ក្នុងទីនោះ លុះភ្ញាក់ព្រះស្មារតីឡើងហើយ ទើបទ្រង់អារកាត់សេចក្ដីសោកដោយព្រះអង្គឯងថា ៖

ការជួបជុំគ្នានឹងការព្រាត់ប្រាសគ្នានេះ ជាធម្មតារបស់សត្វ-
លោកទេតើ! បណ្ឌិតរមែងដឹងខ្លួនតាមសភាពពិតយ៉ាង
នេះ បានជាមានសេចក្ដីសង្វេគក្រៃពេក ។

លំដាប់ពីនោះមក ព្រះអង្គទ្រង់មានព្រះអស្សាសៈធូរស្រួលហើយ ទ្រង់ក៏ចុះទៅកាន់ស្ទឹងវិញ ។

តទា កាលេ កាលនោះមាននាយសំពៅម្នាក់ បើកសំពៅទៅប្រែបន្ទេរស្ទឹងជាមួយនឹងពួកចំណុះសំពៅប្រហែលប្រាំរយនាក់ បានឃើញនាងទេវីបរិបូណ៌ដោយលក្ខណៈ មានរូបល្អចំណាប់អង្គុយនៅក្រោមម្លប់ឈើ ក៏ឡើងទៅចាប់យកនាងមកដាក់ក្នុងសំពៅហើយបើកទៅ ៗ គ្រានោះ ព្រះនាងទេវី ហាក់ដូចជាមានព្រះហឫទ័យប្រេះឆាបែក សព្វែកចេញជា ៧ ភាគ ព្រោះព្រះនាងទ្រង់រឭកព្រះរាជបុត្រទាំងពីរ ព្រមទាំងព្រះស្វាមី ទើបក្សត្រីទ្រង់ព្រះកន្សែងសោកថា:

វិយោគោ មេ កតោ បុព្វេ តរយី មិគបក្ខិនោ
តេន កម្មវិបាកេន វិយោគោ បតិនា សហ

ឱ! អាត្មាអញអើយ! ប្រាកដជាធ្លាប់ព្រាត់ពួកសត្វម្រឹគបក្សីពីជាតិមុនមក បានជាត្រូវព្រាត់ប្រាសចាកកូនពន្លក ព្រមទាំងស្វាមី, ដំណើរនេះ ប្រាកដជាផលកម្មនោះឯងស្វែងតាមមកទាន់ផ្តន្ទាយើង ឲ្យព្រាត់ប្រាសគ្នាយ៉ាងនេះ ៗ នាយសំពៅក៏ប្រឹងតែបើកសំពៅ នាំព្រះនាងទៅកាន់ទីតាមសេចក្តីប្រាថ្នារបស់ខ្លួន ៗ

ចំណែកខាងព្រះពោធិសត្វ ទ្រង់ធ្លងទឹកស្ទឹងឡើងមករកព្រះនាងទេវីនៅទៀបដើមឈើនោះមិនឃើញ ទើបទ្រង់ស្ទុះទៅមកៗស្វែងរកក្នុងទីជិតៗសព្វកន្លែង ក៏នៅតែមិនឃើញទៀត ទើបព្រះអង្គទ្រង់ព្រះកន្សែងថា៖

ឱ! អាត្មាអញអើយ! ជាមនុស្សអនាថា កំព្រាកណ្តោចកណ្តោងតែម្នាក់ឯងស្ងាត់ឈឹង នៅប្របមាត់ស្ទឹងនេះតើហ្ន៎! បាបតែពុត្រាកំសត់កម្រ ព្រាត់ប្រាសឃ្លាតបាត់ពីខ្លួនទៅ ឥឡូវអញរកករិយាមិនឃើញទៀត! ឱះ ឱ កម្មអើយ! ម្តេចឡើយបានជាយើងរងទុក្ខ ខ្ចាត់ភ្លាត់ប្រាសព្រាត់ទៅតែឯង ៗ ដូច្នេះ? បើតែម្ល៉េះ ៗ អញស្លាប់ក្នុងទីនេះទើបប្រសើរ, រស់នៅតែម្នាក់ឯងដូចម្តេចកើត! ម្នាលនាងទេវីជាទីពេញហឫទ័យ, បងមកនៅក្នុងព្រៃស្ងាត់សូន្យឈឹង តើបងនឹងធ្វើដូចម្តេច? បងរំងិតតែសង្រេងសង្រែខ្លាំងឡើង ៗ យ៉ាងនេះដូចម្តេចឡើយនឹងរួចចាកសេចក្តីទុក្ខនេះបាន? ឱះ ឱ ទេវតាអើយ, អ្នកទាំងឡាយឋិតនៅលើភ្នំ លើទីភូមិភាគពសុធា លើអាកាសវេហាស៍ឬលើទីណា ៗ ក្តី ឥឡូវនេះមានតែអ្នកទាំងឡាយហ្នឹងហើយជាទីពឹងរបស់ខ្ញុំ, ធ្វើម្តេចឲ្យខ្ញុំបានឃើញនាងកេសនី? នរណាអើយជាទេព្តា ឬ មនុស្ស ឬយក្សដែលមានឫទ្ធិច្រើន អាចដោះខ្ញុំឲ្យបានរួចចាកសេចក្តីទុក្ខ, អ្នកនោះនឹងជាទីពឹងរបស់ខ្ញុំតទៅ ។

ព្រះបរមពោធិសត្វទ្រង់ព្រះកន្សែងរៀបរាប់ដូច្នេះហើយ ក៏ទ្រង់ដួលសន្លប់បាត់ព្រះស្មារតីក្នុងទីនោះ; លុះទ្រង់មានព្រះអស្សាសៈធូរ

ស្រួលបន្តិចឡើងហើយ ក៏ហាក់ជាទីងងុតព្រះហឫទ័យ ។ តមត្ថំ បកាសេន្តោ សត្ថា អាហ កាលអង្គសម្ដេចព្រះបរមសព្វជ្ញសាស្ដាចារ្យ ទ្រង់ប្រកាសសេចក្ដីនោះ ទ្រង់ត្រាស់ដូច្នេះថា ៖

កន្ទិត្វា វិលប្បិតា ជាតោ បិត្តលតាវនេ
បរិទេវន្តោ សោ រាជា តត្ថេវ បតិតោ ឆមា

ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែងសោយសោកបោកខ្លួនដួលទៅលើផែនដីកន្លែងនោះ ដូចជាដើមចេកដែលដុះកន្លែងព្រៃបិត្តលតាវ័ន ត្រូវខ្យល់ព្យុះបោកកំទេចដួលខ្ទេចខ្ទាំ ។ លុះព្រះមហាសត្វទ្រង់មានព្រះអស្សាសៈ ដកដង្ហើមធូរស្រួលហើយ ទើបទ្រង់ក្រោកឡើងពាក្យនោះ សុះទៅរកខាងនេះខាងនោះ មិនឃើញព្រះនាងទេវីព្រមទាំងព្រះរាជបុត្រទាំងពីរសោះ ទើបទ្រង់ព្រះកន្សែងសោករៀបរាប់ទៀតថា:

នែទេវ្ដាអើយ! ខ្ញុំមិនឃើញកូនទាំងពីរព្រម ទាំងភរិយារបស់ខ្ញុំឡើយ ប្រហែលជាសត្វសាហាវឆាបចាប់យកទៅធ្វើជាចំណីអាហារទេដឹង? ឬមួយទារករបស់ខ្ញុំស្លាប់បាត់ដោយខ្លួនឯងទេ? នែទេវ្ដា! ប្រាកដជាសត្វឆ្កែកម្រើមចឹកសម្លាប់ជនទាំងនោះកុំឲ្យខ្ញុំរកឃើញមែនហើយ ទារករបស់ខ្ញុំស្លាប់មែនហើយ! នែ! អាត្មាអញ យំសោកយ៉ាងនេះពីរបីលើក

ហើយ, ហឫទ័យរបស់អាត្មាអញសោក ក៏ញ័រចំប្រប់ទាំង ម្ល៉េះ ក៏នៅតែមិនឃើញព្រះរាជបុត្រទាំងពីរ ព្រមទាំងនាងទេវីដែលមានឥន្ទ្រិយល្អឥតខ្ចោះ ។ ពេលនេះហឫទ័យរបស់អញ កំពុងញាប់ញ័រដូចជាអន្ទាក់ក្រឡឹងកែវបក់ល ព្រោះតែមិនឃើញជនទាំងបីនាក់នោះ ។ បើអាត្មាអញមិនបានឃើញជនទាំងបីនេះទេ តែព្រះអាទិត្យអស្ដង្គតទៅក្នុងយប់នោះ ហើយភ្លឺស្វាងឡើងវិញពេលណា អាត្មាអញមុខជាស្លាប់ក្នុងពេលព្រឹកនោះមិនខាន ។

ព្រះមហាសត្វទ្រង់ព្រះកន្សែងសោក រវើរវាយដូច្នោះហើយ ក៏ស្ដេចទ្រង់ត្រេចពីទីនោះ ទៅតែមួយព្រះអង្គ ។

ត្រង់ចន្លោះនេះ មានពាក្យចោទប្រៀតដណ្ដឹងសួរមកថា ក្សត្រទាំងបួនព្រះអង្គ ដែលព្រាត់ប្រាសគ្នាយ៉ាងនេះ ព្រោះបាបកម្មដូចម្ដេច? ពាក្យដោះស្រាយថា កាលពីព្រេងនាយ ក្សត្រទាំងបួនព្រះអង្គនោះ បានទៅអង្គុយនៅទៀបគល់ឈើមួយដើម ត្រង់ចន្លោះផ្លូវដែលខ្លួនដើរទៅ ។ កុមារជាបុត្រទាំងពីរនាក់ បានឮសំឡេងកូនសេក[១]យំលើចុងឈើ ក៏ចង់បានកូនសេកនោះមកលេង, ទើបយំលំអុកឲ្យមាតា ត្រាតែមាតាអត់

---

១ រឿងនេះ អ្នកប្រាជ្ញពីបុរាណបានប្រែទៅជាកាព្យ, ក្នុងរឿងកំណាព្យនោះ លោកប្រែថា "កូនបោលពោក", ប្រហែលជាគម្ពីរដែលលោកយកមកធ្វើច្បាប់ប្រែនោះ មានបាលីថា "នង្គុហបោតកានំ" ដូច្នេះទេដឹង? ~

ព្រាំមិនបាន  ក៏អង្វរស្វាមីឲ្យទៀងយកកូនសេកនោះមកឲ្យកូនលេង. កាលកុមារទាំងពីរលេងកូនសេកនោះ  បានដករោមស្លាបរ រះបាច អស់ចំនង,  កម្មនោះឯងឲ្យផលផ្តល់ឲ្យក្សត្រទាំង ៤ ព្រះអង្គបានដល់នូវសេចក្តីព្រាត់ប្រាសចាកគ្នាយ៉ាងនេះ  អស់កំណត់ ៥០០ ជាតិ ។ តមត្ថំ បកាសេន្តោ សត្ថា អាហ អង្គសម្តេចព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា ៖

តតោ មគ្គធរ រុក្ខេ សុវបោតកំ គហេត្វា
បោកំ បិ ច កុមារា តីណិ (តេសំ) លោមានិ លុញ្ចិំសុ

កុមារទាំងពីរលេងកូនសេក ឲ្យរដកតែរោមបីគត់ ក្បែរផ្លូវនោះ  ក៏កម្មនោះតាមមកឲ្យផលដល់ម្ល៉េះ ។

បិតានោះ  ក៏យកកូនសេកទៅទុកលើដើមឈើវិញ;  ដោយផលកម្មនោះ  បានជាត្រូវព្រាត់ប្រាសចាកគ្នាដូច្នេះ ។

ឯអង្គព្រះបមពង្សក្រុងសុភមិត្ត  ទ្រង់ចេញចាកទីនោះទៅទាំងទុក្ខក្រៀមក្រំ  ដោយសេចក្តីរលឹកនឹកដល់ព្រះរាជបុត្រ  ទឹងអត្តមហេសីណាស់  ទើបត្រាស់ថា ៖

អប្បិយេហិ សម្បយោគោ វិប្បយោគោ បិយេហិ ច
ទុក្ខោ បិយវិយោគញ្ច បរិច្ចិន្ទតិ វឌ្ឍតិ ។

បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
ឯវំ វិសេសតោ ញត្វា ន ករេ បិយពន្ធនំ ។

*ដំណើរសមប្រកបដោយអារម្មណ៍មិនជាទីស្រឡាញ់ក្តី ដំណើរព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ក្តី ក៏សុទ្ធតែនាំមកនូវសេចក្តីទុក្ខ ; បើអាត្មាអញ ផ្តាច់បង់នូវសេចក្តីស្រឡាញ់ចំពោះអារម្មណ៍ ដែលព្រាត់ប្រាសទៅនោះបាន ទើបគួរនឹងបាននូវសេចក្តីសុខ ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីស្រឡាញ់ទាំងអស់ ; បើផុតសេចក្តីស្រឡាញ់ហើយ, សោកក៏គ្មាន ភ័យក៏គ្មាន ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីប្រាថ្នា ; បើផុត*

សេចក្តីប្រាថ្នាហើយ, សេចក្តីសោកក្តី ភ័យក្តីក៏មិនមាន ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីតណ្ហា; បើរួចផុតបាកតណ្ហាហើយ, សេចក្តីសោកក្តី ភ័យក្តី នឹងមានមកពីណា ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីត្រេកអរ; បើអស់សេចក្តីត្រេកអរហើយ, សេចក្តីសោកនឹងភ័យ នឹងមានពីណា? បើបុគ្គលដឹងច្បាស់យ៉ាងនេះហើយ មិនគួរធ្វើបំណងគឺសេចក្តីស្រឡាញ់ ឲ្យជាប់មាំមួនតទៅទៀតឡើយ ។

ព្រះមហាក្សត្រទ្រង់ព្រះកន្សែង សោយសោកដូច្នេះហើយស្តេចក៏ត្រេចចរទៅ ។ កាលព្រះពោធិសត្វ ទ្រង់ត្រេចទៅតាមលំដាប់ ក៏ស្រាប់តែបានដល់នគរតក្កសិលា ហើយទ្រង់ចូលទៅក្នុងឧទ្យានផ្ទំសម្រាកព្រះកាយ លើថ្មមង្គលសិលាទៀបគល់រាំងមួយដើម ។

តទៅ គ្រានោះ ជួនជាព្រះរាជាព្រះចៅនគរតក្កសិលាទ្រង់សោយព្រះទិវង្គតទៅ ។ ពួករាជសេវកាមាត្យ ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីធ្វើព្រះសរីរកិច្ចរួចស្រេច, ដល់ថ្ងៃទី ៧ ក៏ប្រជុំប្រឹក្សាគ្នាក្នុងទីព្រះលានថា "ព្រះរាជាម្ចាស់យើងគ្មានព្រះរាជបុត្រសោះ, តើបាននរណាសោយរាជ្យ? ដែនសីមា បើឥតស្តេចគ្រប់គ្រងថែរក្សាទេ មិនងាយនឹងគង់នៅបានទេ, ឥឡូវនេះ អ្នកក្តី ខ្ញុំក្តី តើនរណាគាប់សោយរាជ្យកើត" ។ ទើបបុរោហិតម្នាក់ឆ្លើយឡើងថា "ត្រូវតែយើងនាំគ្នាផ្សងបុស្សរថ ឲ្យ

ទៅរករើសស្ដេចដ៏ប្រសើរ ទើបគួរ, បើអ្នកណា មានលក្ខណៈមានបុណ្យ-គ្រប់គ្រាន់ គង់តែបុស្សរថនឹងនាំអ្នកនោះមកពុំខាន អ្នកនោះឯងទើបសោយរាជ្យបាន" ។ អាមាត្យទាំងនោះ ក៏ទទួលព្រមថា សាធុ ហើយលើកគ្រឿងបញ្ចកកុធភណ្ឌដាក់លើបុស្សរថនោះ ។ បុរោហិតលែងបុស្សរថតាំងផ្សងថា

ឆត្តំ ចាមរិ ឧណ្ហិសំ ខគ្គំ សុវណ្ណបាទុកំ
ឥមានិ បញ្ចភណ្ឌានិ រាជូនំ អភិសេកត្តិ

"គ្រឿងបញ្ចកកុធភណ្ឌ ៥ យ៉ាងគឺ ឆត្រ ១ ផ្លិត ១ មកុដ ១ ព្រះខាន់ ១ សុពណ៌បាទុក ១ នេះជារបស់សម្រាប់អភិសេកព្រះរាជាទាំងឡាយ (បើអ្នកឯណា មានបុណ្យវាសនា គួរបានជាស្ដេចសោយរាជ្យក្នុងនគរយើងនេះ, សូមឲ្យបុស្សរថទៅឈប់ត្រង់កន្លែងអ្នកនោះ") ។

លំដាប់នោះ បុស្សរថទៅប្រទក្សិណព្រះរាជមន្ទីរហើយចេញទៅតាមទ្វារខាងកើត ។ ពួកមហាជនក៏រៀបចំតូរ្យតន្ត្រីដង្ហែតាមក្រោយទៅ ។ ឯបុស្សរថ ក៏ចូលទៅធ្វើប្រទក្សិណមង្គលសិលា ក្នុងឧទ្យានហើយក៏ឈប់នៅ ។ ខណៈនោះ បុរោហិតក៏ចូលទៅឃើញព្រះមហាសត្វកំពុងផ្ទំលក់លើផ្ទៃមង្គលសិលាតែមួយព្រះអង្គឯង ទើបឲ្យប្រគំភ្លេងតូរ្យតន្ត្រីឡើងដើម្បីល្បងព្រះបរមពោធិសត្វមើល ។ សព្ទតូរ្យតន្ត្រីក៏លាន់ឮឡើងហាក់

ដូចគេក្រឹតផែនក្រឡាមហាប្រឹថពី ។ ទើបព្រះបរមពោធិសត្វក្សត្រឡើង បើកសំពត់ទទូរព្រះសិរសា ទ្រង់ទតឃើញពពួកសេនាយោធា ហើយក៏ទ្រង់ប្រែព្រះកាយផ្គុំធ្វើជាលក់វិញ ។ ព្រាហ្មណ៍បុរោហិត បើកសំពត់សាដកដែលព្រះអង្គទ្រង់ទទូរ មើលលក្ខណៈត្រង់ព្រះបាទាសព្វគ្រប់ប្រការហើយលាន់មាត់ថា "ម្នាលគ្នាយើងដ៏ចំរើន, ចូរអ្នកទាំងអស់គ្នាពិនិត្យលក្ខណៈបុរសនេះមើល, បុរសនេះ ទើបអាចសោយរាជ្យជាស្តេចធំក្នុងទ្វីបទាំងបួនបាន" ។ ពួកមហាជនឮហើយ ក៏នាំគ្នាលើកដៃប្រណម្យដាក់លើសិរសាបង្គំទូលថា "បពិត្រព្រះនរបតីក្សត្រថ្លៃប្រសើរអើយ, សូមព្រះអង្គទ្រង់ទទួលយករាជសម្បត្តិ, សូមព្រះអង្គជាម្ចាស់នៃរាជសម្បត្តិរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមព្រះអង្គគ្រប់គ្រងប្រជារាស្ត្រទាំងឡាយចុះ" ហើយនាំគ្នាក្រាបបង្គំទូលថា ៖

នគរនេះជាទីក្សេមមនោរម្យ សមជាទីសប្បាយ ប្រដាប់
ដោយកំពែងទឹងក្លោងទ្វារល្អឆើតឆាយ ដែលទូលព្រះបង្គំជា
ខ្ញុំទាំងឡាយ បានគ្រប់គ្រងរក្សាទុកដើម្បីថ្វាយដល់ព្រះអង្គ,
ទាំងប្រាសាទដ៏ប្រសើរស្អាងស្អាត រុងរឿងដោយកំពូល
គាងឃ្វាយ ដែលពេញដោយពួកកញ្ញាទាំងឡាយនេះ ក៏
ទូលព្រះបង្គំជាខ្ញុំសូមថ្វាយចំពោះព្រះអង្គដែរ ។

ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ពាក្យមហាជននោះហើយ ក៏ទ្រង់ក្រោកឡើងសន្សឹមៗ ទ្រង់មានព្រះរាជតម្រាស់ត្រាស់សួរថា "ម្នាលអ្នក

ទាំងឡាយដ៏ចំរើន, ចុះស្តេចរបស់អ្នកទាំងឡាយទៅណា?" ។ ពួកមហាជនក្រាបបង្គំទូលស្នងព្រះរាជឱង្ការថា "បពិត្រព្រះសម្មារ, ព្រះរាជារបស់ទូលព្រះបង្គំជាខ្ញុំទ្រង់ព្រះទិវង្គតហើយ" ។ - ចុះព្រះរាជបុត្រព្រះរាជធីតានឹងព្រះរាជវង្សានុវង្សរបស់ព្រះអង្គទៅណា? ។ - សូមទ្រង់ព្រះមេត្តាប្រោស, គ្មានទេ ។ - អើ! បើដូច្នោះ ខ្ញុំនឹងទទួលតាមពាក្យអ្នកទាំងឡាយបាន ។ ពួកមហាជនព្រះរាជឱង្ការគ្រាស់ទទួលហើយ ក៏រៀបអភិសេកក្នុងទីនោះ ។ ព្រះអង្គទ្រង់ចេញដោយព្រះយសជាអស្ចារ្យ ទ្រង់ស្តេចទៅក្នុងទីណា ក៏ទីនោះគេត្រេកអរតែកញ្ចាប់ញ័រ ។ ពពួកមហាជនប្រគំភ្លេងតូរ្យតន្ត្រីឡើង ពួស្ទូរស័ព្ទទ្រហឹងអឺងអាប់ហាក់ដូចជាសូរស័ព្ទរលកក្នុងផ្ទៃមហាសមុទ្រ ។ ពួកអាមាត្យក៏នាំព្រះអង្គមកកាន់ព្រះនគរ ពោមពេមឈូឆរហែឡើងទៅលើប្រាសាទស្អាតសោភា ។ ទើបព្រាហ្មណ៍បុរោហិតនាំគ្នាចូលទៅក្រាបបង្គំទូលអំពីចំនួនព្រះរាជទ្រព្យ ដែលមាននៅគ្រប់គ្រមថា ៖

នេះពលដំរី នេះពលសេះ នេះពលរថ នេះពលថ្មើរជើង

ព្រមទាំងព្រះរាជនិវេសន៍នេះផង ទាំងស្រីព្រះស្នំដែលស្អិតស្អាងតែងអង្គចាំគាល់បំរើនេះផង ទូលព្រះបង្គំទាំងឡាយសូមថ្វាយចំពោះព្រះអង្គ, សូមទ្រង់ទទួលប្រើប្រាស់តាមសព្វព្រះរាជហ្ឫទ័យ ។

តាំងពីពេលនោះរៀងមក ព្រះអង្គទ្រង់ធ្វើការកុសលមានទានជាដើម ព្រះអង្គទ្រង់សោយរាជ្យប្រកបដោយទសពិធរាជធម៌ ឥតមានមោះមន្ទិលឡើយ ។

ចំណែកខាង ព្រានសំណាញ់តាំងពីរនាក់ បីបាច់ថែរក្សាព្រះរាជបុត្រទាំងពីរព្រះអង្គ ដូចកូនដែលកេចចេញពីសាច់របស់ខ្លួន ។ លុះកុមារទាំងនោះចំរើនធំឡើង ព្រានសំណាញ់ក៏នាំកំស្តុការបណ្ណាការទៅក្រុងតក្កសិលាថ្វាយកុមារទាំងពីរនោះឲ្យជាខ្ញុំរាជការ ។ គ្រានោះ ព្រះរាជាទ្រង់ឃើញកុមារទាំងពីរនោះហើយ ទ្រង់ត្រាស់សួរថា "កុមារទាំងពីរនេះកូនអ្នកណា?" ។ ព្រានសំណាញ់ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស កូនរបស់ទូលព្រះបង្គំជាខ្ញុំ" ។ ព្រះរាជាទ្រង់ត្រាស់សួរទៀតថា "ម្តេចក៏កុមារទាំងនេះមានរូបល្អល្អះ គួរជ្រះថ្លាគួរពេញចិត្តរមិលមើលដល់ម៉្លេះ មិនស្រដៀងនឹងអ្នកទាំងឡាយសោះដូច្នេះ?" ។ – សូមទ្រង់ព្រះមេត្តាប្រោស, កុមារទាំងនេះគាត់បានទៅខាងម្តាយ ។ លំដាប់នោះព្រះរាជាទ្រង់ព្រះចិន្តាថា "ឱ! កុមារទាំងនេះដូចកូនអញណាស់តើហ្ន៎! បើសិនជាកូនអញនៅ ល្មមលើកមកធៀបនឹងគ្នាបាន" ក៏ព្រះអង្គមានព្រះរាជហឫទ័យស្រឡាញ់កុមារទាំងនោះដូចជាព្រះរាជបុត្រ ។ ២កុមារទាំងនោះក៏មានប្រាជ្ញាស្មារតីឆ្លៀវឆ្លាតសមគួរជាព្រះអង្គម្ចាស់ ។ ព្រះរាជាទ្រង់ឃើញឫកមារយាទកុមារនោះល្អ ក៏មានព្រះរាជហឫទ័យជ្រះថ្លារីករាយ ទ្រង់ប្រទានយសសក្តិឲ្យឡើងជានាយត្រួតការ ។ (មានត)

# រឿងសៅរ៍សោយ

(សិរិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រស្លឹករឹត

(តមក)

---

ស្ដេចអត់ក្រយាស្ងោយ ពុំបានសោយតិចឡើយនៃ
សន្ធឹករឹងសន្ធៃ កៀកមនោម័យហើយសោកា ។
ស្ដេចទ្រង់ព្រះកន្សែង ព្រះឱស្ឋថ្លែងទៀងថ្ងូញថា
"ឱះឱ ! គួរអនិច្ចា ខ្លួនកាត្ងាមកវិបត្តិ ។
ប្រាសព្រាត់នគរ មកវេទនាពន់ពេកក្ដាត់
ផងទោសរងវិបត្តិ ប្លែកត្រកាលកណ្ដាលព្រៃ ។
រីទុក្ខទាំងនេះណា ជាផលាកម្មចង្រៃ
ពុំគឺអ្នកដទៃ គឺអញឯងធ្វើមកណា ។
ព្រោះអញគ្មានជំនឿ ពុំព្រមជឿពាក្យហោរា
ទើបរងវេទនា ក្នុងវេលាគ្រានេះឯង ។
ឱះឱ !ខ្លួនអញអើយ ពុំគួរឡើយមកចំបែង
ធ្លាប់នៅទីកន្លែង បុរីរម្យសមសំពន្ធ ។

កាលដល់យាមព្រះស្ងោយ តែងធ្លាប់សោយដោយសុខសាន្ត
ក្នុងភាជន៍មាសច្រើនថ្កាន ពុំដែលមានក្តីសៅហ្មង ។
យាមផ្ទំៗសុខសែន លើព្រះខែនល្អកន្លង
សឹងក្រាលកម្រាលផង មានសម្ពស្សទន់ត្រជាក់ ។
យាមគង់ៗបល្ល័ង្ក មានគ្រឿងតាំងសឹងចំឡាក់
មន្ត្រីទូវសេវក ស្តុំគំនាល់គាល់ត្រៀបត្រា ។
ឥឡូវព្រាត់បុរី តើបានអ្វីគ្រាន់ភោគ្គា
មានតែទុក្ខវេទនា ជាតំណាងគាងចំណី ។
ពេលដេកត្រូវដេកលើ ពូកស្លឹកឈើក្រាលផ្ទាល់ដី
ពេលគង់ៗទុក្ខី ក្រោមដើមជ្រៃតែឯកា ។
ពុំមានស្តុំគំនាល់ សម្រាប់គាល់ដូចធម្មតា
មានតែសេះទេះណា ជាសំឡាញ់រួមសុខទុក្ខ ។
ទឹងមានតែចន្ទ្រា ជាផ្កាណាជួយឲ្យសុខ
ជំនួសក្មេងគ្រប់មុខ ដែលធ្លាប់មានក្នុងបុរី ។
ឮតែសូរសត្វយំ ក្នុងទូរគមជួសតន្ត្រី
យកតែសត្វបក្សី ជារបាំប្រចាំប្រាណ ។
ឱ! ខ្លួនអញឯងនេះ ទុក្ខខ្លាំងម៉្លេះពេញហៅហាន
តើខ្លួនអញទឹងបាន វត្ថុអ្វីគ្រាន់ភោគ្គា ។

អញនឹងអង្គុយលើ ស្មៅស្លឹកឈើម្ដេចទៅក៏
លុះព្រឹកព្រាងសុរិយា បាននរណាបង្ហាញផ្លូវ ៗ
បើអញពុំដឹងថា ទៅខាងណាទើបបានត្រូវ
បើដោះអញនេះគួរ គង់តែត្រូវស្លាប់ជាម្ដង ៗ
គិតហើយរឹងតែគិត អញអាណិតតែខ្លួនល្អង
អានន្ទទេវីបង នាងនឹងបានតែក្ដីទុក្ខ ៗ
នាងមិនឃើញអាត្មា ជាកស្ដាផ្ដាប់ម្លសុខ
ពីថ្ងៃនេះទៅមុខ មានតែទុក្ខជាអំណោយ ៗ
នាងនឹងក្ដួចស្លាងអង្គ ក្ដួចស្រះស្រង់ក្ដួចព្រះស្វាយ
ហើយនាងនឹងត្រូវសោយ តែទឹកនេត្រជួសកោធន ៗ
ខ្វះខ្វស្រស់ប្រិមប្រិយ ម៉្លេះសមស្រីនាងទុក្ខជូន
ឥតថ្លៃឥតស្រាកស្រាន់ ទំរាំជួបនឹងរៀមរ៉ក” ៗ
ស្ដេចសោក ៗ រៀបរាប់ តាមតែគាប់ចិត្តទុក្ខដាក់
ស្រេចហើយព្រះចមច្រក ផ្ទៀងព្រះកាយផ្ទំនិទ្រា ៗ
លុះព្រឹកព្រាងស្រេចហើយ ពុំលង់ឡើយព្រះភជា
ស្ដេចតើនចាកនិទ្រា ទើបក្សត្រានឹករំពៃ ៗ
មិនដឹងនឹងដើរទៅ ស្ថានលំនៅឯណាទៃ
ស្ដេចគិតយកមនោម័យ ដឹកកាត់ព្រៃដងអាផ្លា ៗ

សឹងមានស្បូវ ៗ ស្បាត   ផុះញឹកញាត់ច្រើនមហិមា
ឈើផងសឹងបន្ទា   មុតបាទាលំបាកក្រៃ ៗ
ស្តេចយាងទៅពុំបាន   ទើបក្សត្រកាន្តឡើងអាជានេយ្យ
បរកាត់ចំណាយព្រៃ   វង្វេងពុំដឹងមាគ៌ា ៗ
ស្តេចបរព្រះទីនាំង   អស់កំឡាំងទន់កាយា
ស្តេចឈប់បេះផលា   សោយហើយណាបរទៀតទៅ ៗ
ស្តេចទតព្រៃព្រឹក្សា   ច្រើនត្រៀបត្រានាព្រៃជ្រៅ
ដើមដុះប្រែងប្រាងនៅ   ស្តេចគិតទៅដល់ដំណាក់ ៗ
នឹកនាងនាថអានន្ទ-   ទេវីតន់ឆោមវរលក្ខណ៍
ទឹកនេត្រហូរសស្រាក់   ស្រោចព្រះភក្ត្រាដោយព្រៃទៅ ៗ
មើលមានហ្វូងសត្វម្រឹគ   ដើរគគឹករកស៊ីស្មៅ
ស្តេចផ្ទៀងព្រះនេត្រទៅ   ទតអស់ម្រឹគផងទាំងឡាយ ៗ
រមាំង, រមាស, ខ្លា,   គោ, មហិង្សា, ទាំងប្រើស, ទ្រាយ
ទន្សោង, នូវទន្សាយ   ស្វាន, ចចក ទាំងឆ្មា ៗ
ខ្លះបោលកៀងកាល់ញី   ខ្លះរកស៊ីក្រោមព្រឹក្សា
សត្វផងច្រើនណាស់ណា   ក្រនឹងរាប់នឹងគណនា ៗ
ស្តេចទតអស់ទាំងម្រឹគ   ហើយស្តេចនឹកនគរា
ព្រះឱស្ឋថ្លែងខ្លួនថា   "ឱ! អាត្មាអញនេះនៃ ៗ

ធ្លាប់នៅសោយសម្បត្តិ ឥឡូវខ្ចាត់មកដោយព្រៃ
ឃើញតែសត្វទីទៃ ទងដើមពេជ្រដូច្នេះណា ៗ
ឱ! សត្វផងទាំងឡាយ រាសប្បាយដោយព្រឹក្សា
ប្រដេញប្រដោលគ្នា កៀងគូរបោលប្រឡែង ៗ
ខ្លះដេកខ្លះដើរទៅ រកស៊ីស្មៅដោយឥតក្រែង
ខ្លះឈរនៅកន្ទួង កូនប្រឡែងនឹងមេរា ៗ
ក្របីឡើងកកល់ អួតគ្នាជល់ដើររេក
ងើយងមករកគ្នា ហោលកន្ទួងលេងសប្បាយ ៗ
គោស្មៀងស្ទុះស្ទុះបោលលេង លោតកញ្ឆ្រងជើង៤ប្រាយ
ដីជាប់ដូចគេកាយ បោលទៅឆ្ងាយហើយវិលវិង ៗ
ឱ!សត្វផងទាំងឡាយ រាសប្បាយអឺម៉ឹង ៗ
អនិច្ចាខ្លួនអញហ្នឹង កើតទុក្ខតឹងម្នាក់ឯងណា ៗ
ឱ!កម្ម ៗ ពីព្រេង ឲ្យអញឯងកើតទុក្ខា
ម្នាក់ឯងតែឯកា ឥតអ្នកណាជាពីរផង ៗ
មានតែសេះនេះណា បានជាគ្នានឹងអញហោង
ដឹកហើយជិះលើខ្នង ឥតមនុស្សផងជា ២ នាក់" ៗ
ស្ដេចសោកហើយអនិច្ចា ទឹកនេត្រាហូរស្រោក
ជលនេត្រស្រោចព្រះភក្ត្រ ហូរហៀរធ្លាក់សព្វដោយព្រៃ ៗ

ស្តេចយាងសោកបណ្តើរ ក្សត្រប្រសើរទល់ទុក្ខក្រៃ
ព្រះនេត្រារំពៃ ឃើញសត្វព្រៃច្រើនត្រៀបត្រា ។
គោព្រៃនូវញី បួរអូសដីសម្បុរព្រា
ស្នែងស្រួចដូចបន្ទា ច្រើនត្រៀបត្រាញីឈ្មោលផង ។
ឯឈ្លូសឱនស៊ីស្មៅ ខ្លាលបទៅពីក្រោយខ្នង
លោតទះឈ្លូសជាម្តង ខុសឯឈ្លូសត្រូវតែដី ។
ឯឈ្លូសស្ទុះបោលទៅ ចូលព្រៃជ្រៅនៅភហី
ខ្លាសោតលោលោតចុ លឡ្យកស្នៀតវីតែឯង ។
ជ្រូកព្រៃច្រើនឥតបី ឱនឈូសដីខ្ទះទន្ទ្រង
កញ្ជ្រោងលោតប្រឡែង ដេញគ្នាឯងលេងសប្បាយ ។
កីលែននូវកីកា ទាំងអូដ្ឋលាផងទាំងឡាយ
ដោយបនដោយហ្វូងហ្វាយ ដើររៀងរាយច្រើនក្រៃលែង ។
ស្តេចទតអស់សត្វផង ច្រើនកន្ទុងគួរស្ញប់ស្ញែង
ក្នុងទ្រូងរឹងចំបែង ខ្លាចដំរីមាសខ្លា ។
ស្តេចហួសពីនោះទៅ ចូលព្រៃជ្រៅដងអាង្វា
មើលមានព្រៃព្រឹក្សា ដើមក្រស្នាក្លាំពាក់ផង ។
ចំប៉ីនូវចម្ប៉ា ទាំងក្តាំងផ្កាតុំសែនហោង
ថ្កឹក, រាំង, ត្រាំង, ក្ទួង, ស្តីស្តៅផងអង្កាញ់ណា ។

ព្រីង,ព្រុស,ស្វាគស្វាយចន្ទ ក្រុបក្រញូងចន្ទន៍ក្រស្នា
ទន្ទាប់នូវទន្ទា ប្រេស, អង្គា, អង្កោល, ត្នោត ។
ទ្រាស្នៅនូវសណ្ដាន់ ដែលលំពាន់លំពស់ពោត
ក្រកោះក្រឡាញលោទ ត្រាចត្បែងខ្ទុងពង្រៃឃ្វ ។
ស្ដេចយាងចៀងទេត្រា យល់ព្រឹក្សាស្រោងត្រៃឈើ
ត្រឈឹងលូតលៃ សត្វផងទំយំទ្រហឹង ។
ស្ដេចស្ដាប់សត្វមាត់រៃ យំគ្នុងព្រៃរណ្ដឹង
ព្រះនេត្រស្ដេចសំឡឹង ឃើញក្ងាពំងទំទន្ទា ។
ត្រសេកត្រសេះទំ សត្វសេកយំទំដើមទ្រា
ពក្វាក់ទំពក្វា សត្វទទាទំដើមស្ដៅ ។
សារិកាហើរទៅទំ ចាប់ទ្រទំដើមតាត្រៅ
លលកហើរសំដៅ ចុះទំនៅដើមពងក្ន ។
សត្វសេកសោមបណ្ឌិត ទំនៃបទិត្យដើមស្ប្រុំ
ពពូលហើរទៅទំ ឆាដើមកុម្ពក្បែរដើមក្រ ។
ទ្រមែងខ្វែងទំមែក គ្រលែងរែកទំដើមញ
ពពេចទំពក់ស រន្ធពង្រពង្រូលនៅ ។
ករវិកយំពីពោះ ហើរផ្ទុកផ្ទោះទំដើមញ៉ៅ
រនេ្ទួបចៀងឆាបទៅ ចុះទំនៅដើមក្រសាំង ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៩

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ឯម៉ាថេងចៅហ្វាយស្រុកសែលៀងដែលចូលទៅនៅក្នុងក្រុងហ្វូគោនោះ បានរួមគំនិតនឹងឡេពី, តាំងស៊ុន ដើម្បីនឹងរំលាងកំចាត់ចូចូចេញតាមឡាយព្រះហស្ដព្រះចៅហៀនតេ ។ លុះឡេពីលើកទ័ពចេញទៅហើយ ទទួលមានបំរើចូលទៅប្រាប់ម៉ាថេងថា ឥឡូវមានកើតសឹកក្នុងស្រុកសែលៀង ។ ម៉ាថេងក៏ចូលទៅក្រាបបង្គំលាព្រះចៅហៀនតេហើយប្រមូលកងយោធារបស់ខ្លួនលើកចេញទៅស្រុកសែលៀង ។ ឯឡេពីកាលលើកទ័ពទៅដល់ស្រុកឈីជីវ គឺម៉ៅដែលចូចូឲ្យនៅរក្សា

ស្រុកនោះដឹងថា ឡេវពីលើកទ័ពមកក៏ចេញទៅទទួលនាំចូលទៅក្នុងទីគេហស្ថាន ហើយឲ្យរៀបតុះតៀងភោជនាហារ ។

ឯស៊ុនខៀននឹងប៊ីតុកដែលនៅរក្សាគ្រប់គ្រងភរិយាបុត្រឡេវពី លុះដឹងថា ឡេវពីត្រឡប់មកក៏មានសេចក្ដីត្រេកអរណាស់, នាំគ្នាទៅជួបនឹងឡេវពី ហើយពណ៌នារាយរឿងពីសេចក្ដីសុខទុក្ខគ្រប់គ្រងរបស់ឡេវពីជាប្រក្រតី ។ ឡេវពីក៏មានសេចក្ដីសោមនស្សសាទរណាស់ លាគីម៉ៅទៅកាន់ទីគ្រប់គ្រងរបស់ខ្លួន ។

ខណៈនោះ មានបំរើសេះចូលមកប្ដឹងពីកិច្ចការ ដល់ឡេវពីថា អ៊ួនស៊ុតធ្វើការទុច្ចរិតអាក្រក់ លុយប៊ុតនឹងគាន់ឡាន់ដែលជាសេនាអ៊ួនស៊ុតបានសេចក្ដីក្ដៅក្រហាយ ក៏នាំកូនទាហានរត់ទៅនៅធ្វើចោរក្នុងព្រៃ ឥឡូវអ៊ួនស៊ុតលើកគ្រប់គ្រងនឹងសារពើទ្រព្យសម្បត្តិ នាំយកត្រាសម្រាប់រាជ្យនឹងទៅប្រគល់ឲ្យអ៊ួនសៀវជាបង បានមកដល់ព្រំដែនស្រុកឈីជីវហើយ ។ ឡេវពីបានឮដូច្នោះ ក៏នាំពលទាហានលើកចេញពីស្រុកឈីជីវទៅ បានប្រទះនឹងកងទ័ពគីឡេងជាទ័ពស្រួចនៃអ៊ួនស៊ុត ។ តៀវហ៊ុយក៏បរសេះចូលទៅច្បាំងនឹងគីឡេងបាន ១០ ក្បួន តៀវហ៊ុយស្រែកគំហកដោយសំឡេងខ្លាំង សេះគីឡេងក៏ភ្ញាក់ស្ទុះថយក្រោយ តៀវហ៊ុយបានកលការ ក៏ដេញចូលទៅយកជាវកាប់គីឡេងធ្លាក់ពីលើសេះស្លាប់ ។ ទាហានគីឡេងក៏បែកខ្ចាត់ខ្ចាយរត់ទៅដល់អ៊ួនស៊ុតៗ ដឹងថាគីឡេងស្លាប់ក៏ទឹកខឹងណាស់ បង្ខំលើកទ័ពធំចូលមកតនឹងទ័ពឡេវពី ។

ឡេវពីក៏ប្រើគួនអ៊ូ, តៀវហ៊ុយជាទ័ពប៉ែកស្តាំ ឲ្យជូឡេងនឹងឡៀវជាទ័ពប៉ែកឆ្វេង ឡេវពីជាកងកណ្តាល ហើយបង្គាប់ឲ្យទ័ពប៉ែកស្តាំនឹងឆ្វេងថា បើឃើញអ៊ិនស៊ុតច្បាំងដេញយើងមក អ្នកទាំង ២ កងចូរលើកកងទ័ពខ្ទប់ពីក្រោយទាំងសងខាងឲ្យមាំមួន ។ លុះអ៊ិនស៊ុតលើកទ័ពមកដល់ ឡេវពីក៏បរសេះចេញទៅមុខទាហាន ហើយស្រែកជេរអ៊ិនស៊ុតថា អាក្បត់ ម៉ឹងមិនដឹងថ្ងៃនេះនឹងស្លាប់ទេឬ? ម៉ឹងបានត្រាសម្រាប់រាជ្យហើយ តាំងខ្លួនជាស្តេច ឥឡូវព្រះចៅហៀនតេឲ្យអញលើកកងទ័ពមកបង្ក្រាប បើអាឯងស្រឡាញ់ជីវិតចូរប្រញាប់ចុះមកពីលើសេះមកគំនាប់អញ បើអាឯងនៅរឹងទទឹងមិនព្រមចំណុះអញទេ អាឯងព្រមទាំងញាតិសារលោហិតនឹងស្លាប់ទាំងអស់គ្នា ។

អ៊ិនស៊ុតបានឮដូច្នោះខឹងណាស់ "ក៏ស្រែកជេរឡេវពីថា ខ្លួនអាឯងអួតថាកាន់ព្រះតម្រាស់ នឹងឲ្យអញចំណុះចុះចាញ់នោះ អញមិនត្រូវការទេ ថ្វីដៃអាឯងយ៉ាងណាអញក៏ដឹងហើយ អាឯងធ្លាប់សម្លាប់នរណាស្លាប់ខ្លះ?" ថាហើយអ៊ិនស៊ុតក៏បង្ខំបរពលចូលតយុទ្ធនឹងទ័ពឡេវពីជាកោឡាហល ។

ឡេវពីក៏បរពលចូលហើយធ្វើជាថយត្រឡប់ទៅក្រោយ អ៊ិនស៊ុតឃើញបានការ ក៏ដេញទាហានកាប់ឆ្កាចូលទៅ ឡេវពីក៏បរពលទល់គ្នា ប្រទាក់ប្រកាប់ជាប់ដៃទៅវិញទៅមក ។ គួនអ៊ូ, តៀវហ៊ុយនឹងជូឡេង,

ឡៀវដែលជាបែកឆ្វេងស្តាំ ឃើញបានការហើយក៏បរពលចូលវាយខ្ទប់ទាំងសងខាងជុំវិញកងទ័ពអ៊ូនសុត ។ ទាហានឡាវពីដេញកាប់សម្លាប់ទាហានអ៊ូនសុតស្លាប់ពិការជាច្រើន សាកសពដែលស្លាប់នោះគរលើគ្នាដូចជាគំនរអុសឈើពាសពេញប្រថពី ឈាមហូរដេរដាសលើព្រះធរណីជាទីពន្ទឹកមហិមា ។ កងទ័ពអ៊ូនសុតក៏បែកខ្ចាត់ខ្ចាយរត់ព្រាត់ព្រាយពីគ្នាអស់ទៅ ។

ឯលុយប៊ិកនឹងតាន់ឡាន់ដែលជាសេនាអ៊ូនសុត រត់ទៅធ្វើចោរព្រៃនោះលុះឮថា អ៊ូនសុតច្បាំងគ្នានឹងឡាវ លុយប៊ិកនឹងតាន់ឡាន់ក៏លើកពួកចោរទៅវាយយកទ្រព្យរបស់ នឹងស្បៀងអាហាររបស់អ៊ូនសុតបានជាច្រើន ។ ពេលនោះ អ៊ូនសុតដែលបែកទ័ពខូចខាតគ្រឿងសស្ត្រាវុធនឹងស្បៀងអាហារដឹងថា ពួកចោរទាំងឡាយលើកគ្នាទៅស្ទាក់វាយដណ្តើមយកទ្រព្យរបស់នឹងស្រូវអង្ករស្បៀងអាហារអស់ទៅទៀត អ៊ូនសុតក៏នាំគ្រប់គ្រួទៅឈប់នៅតំបន់កាំងតេង សល់ទាហានសុទ្ធតែមនុស្សចាស់ជរាប្រហែល ១ ពាន់ថ្លាយ សល់ស្រូវភោជន៍សាលីប្រហែល ៣០ រទេះ មនុស្សចាស់ជរាទាំងពួងក៏អត់ឃ្លាន ដោយដាច់ស្បៀងអាហារស្លាប់ទៅខ្លះ ដើរសុំទានអ្នកស្រុកបានមកបរិភោគក៏មិនឆ្អែតខ្លះ ។

កាលអ៊ូនសុតទៅនៅក្នុងតំបន់កាំងតេងនោះ ជារដូវគិម្ហន្តក្តៅណាស់ ករិយាបុត្រទាំងឡាយក៏មានចិត្តក្តៅក្តួលខឹងនឹងអ៊ូនសុត ដែលធ្លាប់ធ្វើទុក

ទោសបុកម្ទេញមកពីដើម ក៏យកស្រូវភោជន៍សាលីទាំងសំបកដាំបាយឲ្យអ៊ីនសុតបរិភោគ ៗ អ៊ីសុតក៏ថា យើងលេបមិនចុះទៅក្នុងបំពង់កទេ ឲ្យរកទឹកឃ្មុំមកឲ្យយើងលាយបាយស៊ី ៗ អ្នកធ្វើបាយឮក៏ខឹងឆ្លើយថា នឹងរកទឹកឃ្មុំឯណាបានក្នុងទីនេះ មានតែឈាមមនុស្ស ៗ អ៊ីនសុតឮដូច្នោះក៏មានសេចក្តីតូចចិត្ត ស្រែកគំហកគំរាមដោយសំឡេងខ្លាំង ក៏ក្អួតឈាមចេញមកប្រហែល ១ នាឡិ ដួលធ្លាក់ពីលើគ្រែក៏ដាច់ខ្យល់ស្លាប់ក្នុងទីនោះ កាលអ៊ីនសុតស្លាប់នោះ ព្រះចៅហៀនគេ យាងទៅគង់នៅក្រុងហ៊្វូគោបាន ៤ ឆ្នាំ ៨ ខែ ៗ

ឯអ៊ីនអ៊ុនជាក្មួយឃើញអ៊ីនសុតជាមាស្លាប់ ក៏លើកសពដាក់លើក្តារមឈូសហើយនាំគ្រប់គ្រួនឹងត្រាសម្រាប់ពង្ស ត្រឡប់ទៅស្រុកឡាំយ៉ុងលុះទៅដល់ស្រុកលោកាំង ឈ្មោះឈើជីវប៉េងពួកអ្នកស្រុកលោកាំងដឹងសេចក្តី ក៏លើកបក្សពួកទៅស្កាត់ពយអ៊ីនអ៊ុន ឈើជីវប៉េងក៏សម្លាប់អ៊ីនអ៊ុននឹងគ្រប់គ្រួអ៊ីនសុតស្លាប់ទាំងអស់ ហើយយកត្រាសម្រាប់ពង្សនោះទៅឲ្យបញ្ជូនក្រុងហ៊្វូគោ ៗ បូបបានត្រាសម្រាប់ពង្សនោះក៏មានសេចក្តីសោមនស្សត្រេកអរណាស់ ហើយតាំងឈើជីវប៉េងជាចៅហ្វាយស្រុកកោ-ឡេង នឹងឲ្យបំណាច់រង្វាន់ ៗ

ឯឡៅពីលុះដឹងថាអ៊ីនសុតស្លាប់ហើយ ក៏ធ្វើសំបុត្របកឲ្យជូឡេងនឹងឡូដៀវកាន់ចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅហៀនគេ នឹងជូន

ដំណឹងខរាជការឲ្យចូចូប្រាប់តាមដំណើរ ដែលបានច្បាំងនឹងអ៊ួនស៊ុតនោះ រហូតអ៊ួនស៊ុតបែកទ័ពទៅនៅតំបន់កាំងតេង, ឯទាហាន ៥ ម៉ឺននោះឡេវពី សុំទុកនៅរក្សាស្រុកឈីជីវ ។

ដូឡេងនឹងឡេជៀវក៏ទទួលយកសំបុត្រនោះ ស្រូតរូតចូលទៅជូន ចូចូឯក្រុងហ៊ូតោ ចូចូឃើញសំបុត្រដូច្នោះក៏ខឹងណាស់ថា យើងប្រើខ្លួន ទាំង ២ នាក់ឲ្យកាន់កាប់កងទ័ពទៅជាមួយនឹងឡេវពី ហេតុម្ដេចបើខ្លួន ត្រឡប់មកមិននាំយកទាហាន ៥ ម៉ឺនមកផង ក៏ឲ្យនៅនឹងឡេវពីទាំង អស់" ថាហើយក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់ខ្លួនដូឡេងនឹងឡេជៀវទៅនឹង ប្រហារជីវិត ។

ស៊ុនហុកក៏ជំរាបចូចូថា លោកចាត់ប្រើឡេវពីធ្វើជាមេទ័ពកាន់អាជ្ញា សិទ្ធិទៅធ្វើការក្នុងរឿនវគ្គសង្គ្រាម; ឯដូឡេងនឹងឡេជៀវឲ្យធ្វើជាកូនកង ទ័ពនៅក្រោមបង្គាប់ឡេវពីៗ យកទាហាន ៥ ម៉ឺនទុក ហើយប្រើដូឡេង ឡេជៀវឲ្យកាន់សំបុត្រចូលមកប្ដឹងខរាជការនោះ សូម្បីដូឡេងនឹងឡេជៀវ មានជំរះប្រាជ្ញាយ៉ាងណា ក៏មិនអាចនឹងទទឹងបង្គាប់ឡេវពីបាន ដែល លោកនឹងឲ្យសម្លាប់អ្នកទាំង ២ ប្រាណចេញនោះ សូមឲ្យលោកត្រិះរិះ មើលតាមការគួរសិនចុះ ។ ចូចូបានស្ដាប់ក៏យល់ថាត្រូវ ព្រមលើក ទោសដូឡេងនឹងឡេជៀវឲ្យរួចខ្លួន ។ ស៊ុនហុកជំរាបទៀតថា គ្រានេះ លោកក៏បានឃើញច្បាស់ពិតប្រាកដ ថាឡេវពីប្រែចិត្តចេញអំពីលោក

បើនឹងស្មៀមទុកយូរឃើញថា សឹកសត្រូវនេះនឹងកំរើកចិត្តប្រទូសរ៉ាយវិញពុំខាន ។

បុច្ឆូឃើញត្រូវកំធ្វើសំបុត្រសម្ងាត់តាមពាក្យស៊ិនហុកថា, ហើយប្រើមនុស្សទំនុកទុកចិត្តឲ្យនាំទៅឲ្យគីម៉ៅ ។ ដឹងក្នុងសេចក្ដីសំបុត្រនោះហើយកំឲ្យហៅខ្លួន គាន់តេងមកប្រឹក្សា គាន់តេងឆ្លើយថា ការប៉ុណ្ណេះក៏ល្មមនឹងគិតធ្វើបាន ព្រោះឥឡូវឡៅពីចេញទៅតាំងបញ្ចុះបញ្ចូលមនុស្សនៅខាងក្រៅស្រុករាល់ថ្ងៃជានិច្ច ពេលព្រឹកនេះសុំឲ្យលោកចាត់ទាហានទៅបង្កប់ទុកសងខាងផ្លូវ បើកាលណាឡៅពីនឹងវិលចូលមកក្នុងស្រុកវិញកំឲ្យទាហានដែលបង្កប់នោះចេញស្កាត់ចាប់សម្លាប់ចេញ ខ្លួនខ្ញុំបាទនឹងលើកទាហានទៅនៅលើកំពែង បើគួនអ៊ូ តៀវហ៊ុយលើកតាមមក ខ្ញុំនឹងឲ្យទាហានបាញ់ធ្នូទល់ទុកមិនឲ្យគួនអ៊ូ តៀវហ៊ុយ ចូលស្រុកបានការទាំងពួងកំនឹងបានសម្រេចដោយងាយ ។ គីម៉ៅយល់ឃើញត្រូវគាន់តេងកំលាគីម៉ៅទៅជួបនឹងគាន់គុយជាបិតា ហើយពណ៌នាពាក្យរឿងឲ្យស្ដាប់គ្រប់ប្រការ ។ គាន់គុយនិយាយថា ឡៅពីនេះជាមនុស្សមានសតិបញ្ញាណាស់ ទាំងចិត្តថ្លើមក៏ល្អពេះពាយពក់ចាក់នឹងពួកម៉ាក ហើយជាពូជព្រះរាជវង្សព្រះចៅហៀនតេ ដែលបុច្ឆូរិះគិតនឹងធ្វើប្រទូសរ៉ាយឡៅពីនោះ ហើយយើងចូលគំនិតធ្វើការក្រក់នឹងឡៅពីទៀតមិនគួរទេ ត្រូវតែយើងទៅប្រាប់ឡៅពីឲ្យដឹងខ្លួនវិញ នោះទើបជាការប្រពៃ ។

គាត់គេងបានឮបិតាថាដូច្នោះ ក៏ផ្លាស់ត្រឡប់ចិត្តគិតឃើញត្រូវ ផង គាត់គុយក៏ប្រើគាត់គេងឲ្យលបចេញទៅប្រាប់ឡៅពី លុះទៅដល់កណ្ដាលផ្លូវប្រទះនឹងគួនអ៊ូ តៀវហ៊ុយលើកទាហានមកមុន គាត់គេងក៏ថ្លែងរឿងរ៉ាវដែលចូចូមានសំបុត្រមកឲ្យគីម៉ៅសម្លាប់ឡៅពីចេញនោះ ឲ្យគួនអ៊ូ តៀវហ៊ុយ ស្ដាប់គ្រប់ប្រការ ។ គួនអ៊ូ តៀវហ៊ុយ បានឮដូច្នោះខឹងណាស់ ៗ តៀវហ៊ុយថា ដែលគីម៉ៅគិតសម្លាប់បងយើងនោះ ត្រូវតែយើងនឹងធ្វើការកាប់ទំលាយយកស្រុកនេះឲ្យបានជាមុន កុំឲ្យគីម៉ៅវះគិតធ្វើយើងបានមុនឡើយ ។ គួនអ៊ូថា គីម៉ៅនៅក្នុងកំពែងប្រុងប្រៀបរៀបបំរុងសេនាទាហានជាស្រេច យើងនឹងលើកចូលទៅច្បាំងខាងក្នុងគង់នឹងថោះការ ត្រូវតែបង្អង់ឈប់នៅទីនេះសិន ចាំពេលយប់សុំបាត់ការឲ្យទាហានចូចូដែលនៅនឹងយើងនោះ ចូលទៅស្រែកហៅគីម៉ៅថាចូចូប្រើតៀវលៀវឲ្យមកនិយាយការជាប្រញាប់ ឲ្យអញ្ជើញគីម៉ៅចេញមកជួបនឹងបាននិយាយការជាការចាំបាច់កំបាំងបន្តិច លុះគីម៉ៅចេញមកខាងក្រៅក្រុង យើងនឹងលើកទាហានចូលចាប់សម្លាប់ចេញ ៗ គាត់គេងតបថា បើលោកចាប់គីម៉ៅមិនបាន គីម៉ៅមុខជានឹងត្រឡប់ចូលក្នុងក្រុងវិញ ខ្ញុំនឹងឲ្យទាហានបាញ់ធ្នូស្កាត់" ថាហើយគាត់គេងត្រឡប់មករកគាត់គុយ ។

លុះវេលាយប់យាម ២ គួនអ៊ីទើបឲ្យទាហានកាន់ទង់សំគាល់របស់ចូឆូ ចូលទៅដល់ជើងកំពែង ហើយប្រាប់នាយទ្វារថាមហាឧបរាជឲ្យគេវេលៀវមករកតីមៅទឹងប្រាប់សេចក្តីអាថ៌កំបាំងមួយ ។ នាយទ្វារក៏នាំសេចក្តីនោះទៅជំរាបតីមៅ ។ ក៏ឲ្យហៅកាន់តេងមកប្រឹក្សាថា ឥឡូវមានទាហានមកប្រាប់ថា ចូឆូប្រើគេវេលៀវមកហៅយើងឲ្យចេញទៅជួប ប្រសិនបើយើងមិនចេញទៅជួបវេលានេះ បើចូឆូប្រើមកពិតចូឆូក៏នឹងសង្ស័យថាយើងប្រែចិត្តចេញ, បើយើងនឹងលើកទ័ពចេញទៅទាំងយប់ស្ងាត់ដូច្នេះ មិនដឹងច្បាស់ថាគេវេលៀវនឹងមកមែនឬមិនមែន ជាកលឧបាយសឹកទេក៏មិនដឹង ។

កាន់តេងឆ្លើយថា លោកមានប្រសាសន៍នោះត្រូវហើយ ចាំខ្ញុំបាទឡើងទៅមើលលើសែនបន្ទាយសិន ។ តីមៅក៏នាំកាន់តេងឡើងទៅលើសែន ក្រឡេកមើលទៅឃើញទាហានជាច្រើន តែមិនស្គាល់មុខច្បាស់ ចាំបានតែទង់ជ័យសម្រាប់ទ័ពចូឆូ តីមៅស្រែកហៅទៅថា ពេលនេះយប់ជ្រៅណាស់ទៅហើយ មហាឧបរាជប្រើមកដោយហេតុការអ្វី ចាំពេលព្រឹកសឹមជួបនិយាយគ្នា ។

ទាហានគួនអ៊ីស្រែកតបទៅថា មហាឧបរាជប្រើមកជាការអាថ៌កំបាំងនឹងបង្អង់ចាំស្អែកមិនបានទេ ក្រែងឡេពីដឹងខ្លួន ឲ្យលោកបើកទ្វារចេញមកជួប ១ រំពេច នឹងបាននិយាយគ្នាកុំឲ្យឡេពីដឹងការទាន់ ។

គីមៅបានឮដូច្នោះ ក៏មិនអស់សង្ស័យទេ ឯទាហានដែលនៅក្រៅកំពែងនោះក៏ចេះតែស្រែកទៀតឲ្យបើកទ្វារ គីមៅបានឮក៏លើកទាហានបំពានផុតគប់ភ្លើងបើកទ្វារឆ្វេងស្ទាន់ក្នុងចេញទៅហើយស្រែកសួរថា គៀវលៀវនៅឯណា ? ៗ គួនអ៊ូឃើញបានការ ក៏បំផាយសេះចូលទៅត្រង់មុខគីមៅហើយស្រែកថា អាកំណាច ! ៗ គួរឬអាឯងគប់គិតគ្នានឹងចូឆូប្រទូសរ៉ាយបងអញ ៗ គីមៅបានឮដូច្នោះក្រឡេកមើលទៅឃើញគួនអ៊ូខឹងណាស់ញាក់សេះបរចូលច្បាំងនឹងគួនអ៊ូបាន ១០ ក្លេង គីមៅអស់កម្លាំងញាក់សេះថយរត់ចូលស្រុកវិញ ៗ

ឯកាន់គេងដែលនៅលើសែនបន្ទាយ ឃើញគីមៅរត់ចូលមកក៏បង្គាប់ឲ្យទាហានបិទទ្វារស្រុកជាប់ ហើយយកធ្នូបាញ់ចម្រុះទប់ពីមុខ, គីមៅចូលស្រុកមិនបាន ក៏បំផាយសេះទៅតាមជើងកំពែងចៀសទៅ ៗ គួនអ៊ូក៏បរសេះតាមទៅទាន់លើកដាវឡើងកាប់គីមៅធ្លាក់ពីលើសេះស្លាប់ៗ គួនអ៊ូក៏កាត់យកក្បាលគីមៅត្រឡប់មកស្រុកវិញ ហើយស្រែកប្រកាសប្រាប់ទាហានដែលនៅលើសែនថា គីមៅគិតសេចក្ដីអាក្រក់នឹងយើងៗក៏សម្លាប់កាត់យកក្បាលមកហើយ អ្នកទាំងអស់គ្នាបើព្រមចុះចូលធ្វើការជាមួយនឹងយើងក៏ឲ្យបបួលគ្នាចេញមករកយើងដោយល្អចុះ យើងមិនធ្វើអ្វីទេ ៗ ទាហានទាំងពួងបានឮដូច្នោះ ក៏បើកទ្វារចេញមកគំនាប់គួនអ៊ូៗ ឃើញបណ្ដាអ្នកស្រុកឈីជីវចេញមកគំនាប់ ដោយស្រួលក៏មាន

សេចក្តីត្រេកអរណាស់ហាមប្រាមទាហានទាំងពួង មិនឲ្យធ្វើអន្តរាយអ្វីឡើយ ៗ

លុះវេលាព្រឹក គួនអ៊ូក៏ឲ្យតៀវហ៊ុយចូលទៅនៅរក្សាស្រុកឈីជីវ ហើយគួនអ៊ូក៏នាំយកក្បាលគីម៉ៅត្រឡប់ឲ្យឡេវពីមើល ទទួលប្រទះនឹងឡេវពីកណ្តាលផ្លូវក៏បង្ហាញក្បាលនោះ ហើយគួនអ៊ូពណ៌នាកយរឿងដែលគីម៉ៅគិតប្រទូសរ៉ាយឲ្យបានដឹងច្បាស់ ព្រោះតាន់គេងបានឲ្យដំណឹងរឿងហេតុនេះ ៗ ឡេវពីបានស្តាប់គ្រប់ប្រការក៏មានសេចក្តីភ័យបារម្ភណាស់ថាសេចក្តីដែលប្អូនធ្វើដូច្នេះ ប្រសិនបើដឹងដល់ចូចូ ៗ មុខជានឹងលើកកងទ័ពមកធ្វើអន្តរាយដល់យើង។ នឹងគិតប្រការម្តេច? ៗ គួនអ៊ូឆ្លើយថា ទោះបីចូចូនឹងលើកកងទ័ពមកធ្វើអន្តរាយដល់យើង ខ្ញុំបាទនឹងតៀវហ៊ុយអាចហ៊ានសុំយកអាសាស៊ូតប្រាំងនឹងចូចូ ត្រាតែអស់ជំរះប្រាជ្ញារៀងខ្លួន ៗ ឡេវពីបានឮដូច្នោះក៏មិនអស់វិតក្ក ទើបនាំគួនអ៊ូនឹងទាហានទាំងពួងលើកចូលទៅក្នុងស្រុកឈីជីវ ៗ ខណៈនោះតាន់គេងនឹងបណ្តាអ្នកស្រុកក៏នាំគ្នាចេញទៅទទួលឡេវពីទាំងអស់ ៗ តៀវហ៊ុយដឹងថាឡេវពីទៅដល់ហើយក៏ចេញទៅទទួលហើយជំរាបឡេវពីថា គ្រប់គ្រួភរិយាបុត្រគីម៉ៅនោះខ្ញុំបាទសម្លាប់ចោលទាំងអស់ទៅហើយ ៗ ឡេវពីឮដូច្នោះក៏រឹតតែមានបរិវិតក្កទុក្ខព្រួយពន់ប្រមាណថា ប្អូនឯងសម្លាប់គីម៉ៅនិងគ្រប់

គ្រឹមៅអស់ស្បៀងដូច្នេះ មុខជាប្អូននឹងលើកទ័ពមកធ្វើអន្តរាយដល់យើងមិនលែងទេ ។

តាន់តេងជំរាបថា ដែលប្អូននឹងលើកកងទ័ពមកនោះទុកជារខ្ញុំបាទនឹងរិះគិតរកឧបាយកល ធ្វើមិនឲ្យប្អូនប្រទូសរ៉ាយដល់លោកបានឡើយ ។

ទៀវពីក៏សួរតាន់តេងថា អ្នកឯងនឹងគិតធ្វើប្រការម្តេចខ្លះ? ។ តាន់តេង តបថា សព្វថ្ងៃនេះប្អូនបារម្ភគិតតែអួនសៀវពៅហ្វាយស្រុកគីជីវ ១ ទេ ព្រោះអួនសៀវមានទាហានប្រមាណ ១០០ ម៉ឺន មានសេនាឯកនឹងទីប្រឹក្សាក៏ច្រើន ឯស្រុកសេនជីវ, ស្រុកអ៊ីវជីវ, ស្រុកបេងជីវ, ៣ តំបន់នេះជាមណ្ឌលធំ សុទ្ធតែឡើងចំណុះអួនសៀវទាំងអស់ បណ្តាស្រុកតូចៗដែលឡើងដល់ស្រុកទាំង ៣ នោះ ជាលំដាប់ទៅទៀតក៏ច្រើន, បើលោកឲ្យមានសំបុត្រទៅសុំកងទ័ពអួនសៀវលើកមកជួយហើយ ក៏នឹងខ្លាចអ្វីដល់ប្អូននោះ ។

(មានត)

# ណាលៈ និង ទមយន្តី

## រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីត្រឹង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ព្រះនាងខំរត់រកសព្វទីកន្លែង - គ្មានឃើញព្រះបាទនាលៈសោះ ។ ព្រះនាងព្រួយព្រះទ័យ ហើយទឹងមានសេចក្ដីតានតឹងពន់ពេកណាស់ ទ្រង់ព្រះតម្រិះថា: " គ្មានជោគវាសនាអ្នកឯណាអាក្រក់ដូចយើងទាំងពីរនេះទេ ជីវិតយើងរស់នៅដោយលំបាកពន់ពេក " ។

នៅពេលនោះ ស្រាប់តែពស់មួយយ៉ាងធំលោតចេញពីក្នុងជំពូកមួយនៅក្បែរនោះមករុំរិតព្រះនាងមួយរំពេច ។ ព្រះនាងទ្រង់ព្រះកន្សែងជាខ្លាំង ហៅព្រះអង្គឲ្យមកជួយ ប៉ុន្តែគ្មានអ្នកណាមួយជួយសោះ ព្រះនាងមុខជាសុគតដោយឥតក័ព្វតែម្នាក់ឯងក្នុងព្រៃ ។

ព្រានម្នាក់ដែលដើរក្នុងព្រៃ ឮសូរព្រះនាងថ្ងូរក៏រត់ចូលទៅមើល ឃើញព្រះនាងសន្លប់បាត់ស្មារតី ព្រានក៏ហូតដាវកាប់ក្បាលពស់កំណាចដាច់ខ្ទាត់ខ្ទាយចេញ ព្រះនាងក៏ដួលផ្កាប់នៅដី ។ ព្រានរត់ទៅរកទឹកមកស្រប់ព្រះកំភ្លៅថ្វាយព្រះនាង ។ កាលព្រះអង្គមានស្មារតីឡើង, ព្រានក៏ថ្វាយផ្លែឈើព្រះនាងសោយ ហើយក៏សាកសួរព្រះនាងថា: " នាងជាអ្វី នាងមានភក្ត្រស្រទន់ល្អដូចជាភក្ត្រឈ្លូស តើអ្នកណា នាំនាងមកចោល

នៅកណ្ដាលព្រៃដូច្នេះ? នាងមានឫកពារថ្លៃថ្លាណាស់ សមតែនៅគេហដ្ឋានដ៏ឧត្តុង្គឧត្តម ហើយនាងទៅជាស្លៀកសំពត់អាវបែបគោកយ៉ាកទៅវិញ, តើបែជន្យដូចម្ដេចបានជានាងធ្លាក់វេទនាដល់ម៉្លេះ?" ។

ព្រះនាងឃើញថាព្រាននោះជួយសង្គ្រោះព្រះនាង ៗ ក៏មានបន្ទូលប្រាប់រឿងរ៉ាវតាមដំណើរ ហើយទើបមានបន្ទូលអំពីសេចក្ដីវេទនា ។ ព្រានព្រៃស្ដាប់ព្រះនាងមានព្រះឧក្ការៈដោយព្រះសូរសៀងស្រទន់ពីរោះ, ព្រះនាងគ្មានអាវពាក់ទេ លំអព្រះនាងហាក់ដូចជាស្ទើបាំងក្នុងព្រៃ ក៏បណ្ដាលឲ្យកាមរាគដុតពេញពលព្រាននោះៗក៏ស្ទុះចូលទៅស្រវាឱបព្រះនាងមួយរំពេច មានបបូរមាត់ញ័រចំប្រប់ដោយកាមតណ្ហា ។ ព្រះនាងយល់នូវសេចក្ដីប្រមាថមើលងាយដូច្នោះហើយ ក៏ខំស្រែកញ៉ាំអស់អង្គថា: "នាឡ:! នាឡ:! ម្ដេចបានជាមិនមកធ្វើទោសមនុស្សអកុសលនេះទៅ, ឧព្រះរាជស្វាមីសំឡាញ់ខ្ញុំអើយ!" ។ ព្រះនេត្រព្រះនាងសំឡក់ព្រានក្ដៅហាក់ដូចជាចេញភ្លើង ព្រាននោះក៏ចង់លែងព្រះនាងដែរ ប៉ុន្តែស្លាប់តែដួលស្លាប់មួយរំពេច ខ្លួនខ្មៅរលាហាក់ដូចជាដើមរុក្ខជាតិដែលពេលដោយភ្លើងរន្ទះ ។

## ភាគ ទី ២៣

ព្រះនាងទ្រង់ត្រាច់ឡើងភ្នំ ចុះរោលកាត់ព្រៃ កាត់បំការទាំងថ្ងៃទាំងយប់ ។ ព្រះនាងទ្រង់ទតឃើញរូងភ្នំ ដែលមានម្រឹគកាចសាហាវតួនៅ,

យល់កន្ទេនដ៏ល្អអស្ចារ្យដែលមានសត្វបាបប្រើនយ៉ាងពីរោះ ៗ ព្រះនាង
បេះតែបន្លែកហៅព្រះបាទនាលៈគ្មានឈប់ឈរ ប៉ុន្តែព្រះបាទនាលៈទ្រង់
មិនបានឆ្លើយតបព្រះនាងសោះ ព្រះនាងយាងតាមក្បែរមាត់ព្រៃកន្ទុង
កាត់ស្ទឹង ទ្រង់ចុះស្រង់កន្ទុំភ្នំដ៏ថ្លា ៗ ព្រះនាងមានបន្ទូលសួរគ្រប់
មនុស្សដែលព្រះនាងបានជួបថា: "អ្នកបានឃើញព្រះបាទនាលៈផងឬ
ទេ?" ៗ ប៉ុន្តែគ្មានអ្នកណាឃើញសោះ ជួនកាលគេមានធម៌មេត្តាដល់
ព្រះនាង ជួនកាលគេនាំគ្នាសើចរំគន់ ៗ ពេលល្ងាចមួយ ព្រះនាង
អស់ព្រះកាយពលពេកទ្រង់ក៏ឈប់គង់នៅក្បែរមាត់ព្រៃ ព្រះនាងឮស្នូរ
សំឡេងសត្វមួយយំគួរឲ្យខ្លាច ប៉ុន្តែព្រះនាងមិនខ្លាច ទ្រង់ខំកេ្រួចក្តី
ព្រួយដោយទឹកដល់សំដីក្បានព្រៃ នឹងពាក្យសច្ចាធិដ្ឋានរបស់ព្រះបាទ
នាលៈ ដែលទ្រង់ក្រោចនៅពេលនេះ ៗ ខ្លាមួយយ៉ាងធំគ្រហឹមនៅក្បែរ
ព្រះនាង ប៉ុន្តែព្រះនាងគ្មានតក់ស្លុត ព្រះនាងមានបន្ទូលទៅរកសត្វខ្លាថា:
"ឯងប្រែហែលជាស្តេចម្រឹគកន្ទៃព្រៃនេះ! ខ្ញុំឈ្មោះទមយន្តីជាឯកអគ្គម-
ហេសីនៃស្តេចនាលៈ ខ្ញុំមានសេចក្តីព្រួយជាខ្លាំងណាស់ ចូរអ្នកមក
ជួយធ្វើឲ្យខ្ញុំកើតសេចក្តីក្លាហានឡើងវិញ ឱស្តេចសត្វអើយ! ចូរអ្នក
ប្រាប់ខ្ញុំផង តើអ្នកបានឃើញស្តេចនាលៈទេ? តើស្តេចទ្រង់ប្រឈួន
ឬសុខសប្បាយព្រះអង្គទេ? តើទ្រង់ព្រួយព្រះទ័យឬទេ? ហ្នឹងហើយ
ព្រោះតែគេបោលខ្ញុំ, តើព្រះអង្គស្តេចទៅតាមផ្លូវណា? មេ្តចក៏អ្នកនៅ
-

សៀមឈឹង? អ្នកមិនបានឃើញទ្រង់ទេឬ? បើដូច្នេះចូរអ្នកចូលមក ហែកខ្ញុំ ទមយន្តីដែលជាស្រីឥតភ័ព្វជាចំណីអ្នកចុះ ដើម្បីនឹងឲ្យខ្ញុំផុតអំពីសេចក្តីទុក្ខ" ។

ប៉ុន្តែខ្លាដើរចេញធ្វើព្រងើយ ព្រះនាងក៏យាងដើរតទៅទៀត មកដល់ដើមភ្នំមួយព្រះនាងលើកព្រះហស្តពិតទូលថា: "ឱគិរីពិសិដ្ឋដែលជាសសរកន្លោងនៃផែនដី! ខ្ញុំសូមឱនកាយវន្ទាដោយគោរព ខ្ញុំជាកូនស្តេចជាឯកអគ្គមហេសីស្តេច ខ្ញុំឈ្មោះទមយន្តី, ឱគិរីពិសិដ្ឋ! សូមអ្នកឆ្លើយខ្ញុំមក តើអ្នកបានឃើញស្តេចនាលៈដែរឬទេ? តើទ្រង់យាងទៅឯណាទៅហើយ? ទ្រង់មានបន្ទូលយ៉ាងម្តេចខ្លះ? ម្តេចបានជាភ្នំឯងនៅស្ងៀម? ភ្នំមិនបានឃើញព្រះបាទនាលៈទេឬ? ឱពុទ្ធោអើយ? កាលណាទៅ ខ្ញុំនឹងបានឮព្រះសូរសៀងព្រះអង្គដែលមានសូរស្រទន់ពីរោះ គួរឲ្យស្រឡាញ់ដូចជាសូរខ្យល់រំភើយ ដែលសំណូរខ្ទាំងដូចជាសូរពពក, ឱភ្នំដ៏អស្ចារ្យអើយ! ម្តេចបានជាអ្នកមិនមកជួយលំហែទុក្ខខ្ញុំផង" ។ ក្នុងខណៈនោះស្រាប់តែព្រះនាងឃើញកំពូលភ្នំមានពន្លឺដ៏វិសុទ្ធិដូចជាម្កុដ ហើយមានឫសី ៣ អង្គចុះសំដៅមករកព្រះនាង គឺវសិស្ឋ (Vaçishtba,) ភរិគុ Bharigu) នឹងអត្រិ (Atri) ឫសីបញ្ចេញមេត្រីភាពចំពោះព្រះកន្យានៃព្រះនាង ហើយនិយាយថា: "ឱព្រះរាជបុត្រីនៃព្រះបាទភិមៈ អំណាចឫសីអាចធ្វើឲ្យយើងមើលឃើញអនាគតបាន, ព្រះនាងនឹងបានសេចក្តីសុខ

សប្បាយវិញមិនខាន បន្តិចទៀតព្រះនាងនឹងប្រទះបាទនាល: ព្រះនាងនឹងជួបស្តេចនៅពេលដែលទ្រង់រួចអំពីកម្មពៀរ ព្រះនាងនឹងឃើញទ្រង់ពេញដោតកក់សនាព្រះអគ្គ នឹងសោយរាជសម្បត្តិជាយូរអង្វែង កងសេចក្តីពេញចិត្តនៃពួកបណ្តាពស្តែផង, ទ្រង់នឹងធ្វើទណ្ឌកម្មដល់មនុស្សកំណាចប្រទានរង្វាន់ដល់មនុស្សដែលបានបំពេញកុសលដ៏ប្រសើរ ហើយព្រះឥន្ទ្រនឹងថ្វាយពរសព្ទសាធុការដល់ព្រះនាងទមយន្តីនឹងព្រះបាទនាល: " ។ ថាតែប៉ុណ្ណោះឫសីក៏រលាយបាត់ទៅ ពន្លឺក៏ស្ងាប់ទៅវិញ ព្រះនាងទមយន្តីនឹកស្មានថាព្រះនាងទ្រង់សុបិន ។

## ភាគទី ២៤

ព្រះនាងទ្រង់ចេះតែយាងតទៅទៀត ប្រមាណជាពីរបីថ្ងៃក្រោយមក ព្រះនាងយាងមកដល់វិថីមួយយ៉ាងធំទូលាយ ដែលទៅតាមក្បែរមាត់ព្រែក ។ នៅទីនោះ ព្រះនាងឃើញអ្នកដំណើរមួយពួកដើរដំរង់មកកាន់ព្រះនាង មានទំនិញយ៉ាងថ្លៃៗ ផ្ទុកលើខ្នងសេះដែលមានពាក់គ្រឿងយ៉ាងល្អ មានអ្នកបំរើយ៉ាងចំណាប់ ។ ដឹកមុខដំរីដែលមានទំនិញយ៉ាងធ្ងន់ផ្ទុកពីលើខ្នង ។ ព្រះនាងមានសេចក្តីខ្មាសអ្នកដំណើរទាំងនោះណាស់ព្រោះព្រះនាងមានតែសំពត់រវៃមួយ ជាសំលៀកបំពាក់លេចមុខលេចក្រោយ ព្រះនាងស្គាំងស្គម ព្រះបាទព្រះនាងដាច់ឈាមដោយបន្ទាន់ធ្ងន់ សាច់ព្រះនាងក្រលដោយកំដៅថ្ងៃ ព្រះនាងចង់រត់ពួន ប៉ុន្តែ

ឈ្មួញម្នាក់ក្រឡេកឃើញព្រះនាង ហើយធ្វើអាការឲ្យព្រះនាងចូលមកជិត បើសិនជាព្រះនាងរត់គេច តើពួកឈ្មួញនឹងយល់ថាព្រះនាងជាមនុស្សអ្វីទៅវិញ? ។

ពួកឈ្មួញចំគយគន់នាងបែបឆ្ងល់ ព្រោះព្រះនាងទៅលក្ខណៈល្អមានឫកពាជាក្សត្រ សូម្បីព្រះនាងដល់នូវសេចក្តីវេទនាយ៉ាងនេះ, នាយឈ្មួញក៏សួរព្រះនាងថា: ‹‹ នាងជាអ្វី? ម្តេចបានជាមកជួបនឹងយើងនៅទីកន្លែងនេះ? តើយើងគួរអាណិតនាងឬគួរខ្លាចនាងវិញ? នាងមានភាពជាអ្នកលំបាកគោកយ៉ាក ប៉ុន្តែរូបឆោមហោមពណ៌នាងហាក់ដូចជាអាទិទេព, តើនាងជាសមយាចកកំសត់ទេឬ? តើនាងនៅក្នុងទីព្រៃជិតនេះឬ? ចូរនិយាយប្រាប់យើងមក! បើនាងជាអ្នកកំសត់ យើងនឹងជួយយកអាសានាង, បើនាងជាអាទិទេព យើងនឹងសុំនៅក្នុងការទំនុកបំរុងរបស់នាង›› ។

ព្រះនាងលុះទ្រង់ព្រះសណ្តាប់ពាក្យនាយឈ្មួញហើយ ក៏មានទឹកចិត្តក្លាហានបន្តិច ហើយមានបន្ទូលតបថា: “ខ្ញុំមិនមែនជាអាទិទេពទេ ខ្ញុំជាស្ត្រីម្នាក់ដែលមានសេចក្តីវេទនាគ្របសង្កត់ ទោះបីខ្ញុំនេះជាបុត្រីស្តេច ហើយជាឯកអគ្គមហេសីស្តេច, តើអ្នកបានឃើញព្រះបាទនលៈជាប្តីខ្ញុំដែរឬទេ? ខ្ញុំមានសេចក្តីព្រួយនឹងព្រះអង្គបានជាខ្ញុំដើររកព្រះអង្គ, កាលដែលព្រះអង្គទ្រង់សោយរាជ្យនៅប្រទេសនិសធ: គ្មានអ្នកណាអាចផ្ទឹមនឹងទ្រង់បានឡើយ, បើអ្នកបានឃើញ សូមប្រាប់ខ្ញុំផង!” ។

នាយឈ្មួញឆ្លើយថា: "ពុំបានឃើញព្រះអង្គទេ" ហើយក៏សួរទៅពួកអ្នកដំណើរទាំងអស់ថា "មានអ្នកណាបានឃើញទេ" ។ អ្នកទាំងអស់ក៏ឆ្លើយថា "មិនបានស្គាល់ទេព្រះបាទនាលៈនោះ" ។ ព្រះនាងទ្រង់ព្រះសណ្ដាប់ហើយទ្រង់ដកដង្ហើមធំ ហើយព្រះនាងមានបន្ទូលសួរទៅនាយកងវិញថា: "តើក្បួនដំណើរនេះមានបំណងនឹងទៅស្រុកណា?" ។ នាយឈ្មួញឆ្លើយថា: "យើងទៅឯទីក្រុងចេទីស៍ (chédis) ដែលមានស្ដេចព្រះនាមសុវហុ (Suvahu) សោយរាជ្យ ។ ព្រះនាងក៏ទៅតាមក្បួនដំណើរនោះ ។ អ្នកដំណើរទាំងឡាយក៏ប្រកបដោយសេចក្ដីសុខគ្រប់ប្រការ ។ ប៉ុន្មានថ្ងៃក្រោយមកគេបានទៅដល់មាត់បឹង ១ ដែលមានទឹកត្រជាក់ល្អហើយនឹងមានផ្កាឈូកដេរដាស កន្លែងនោះជាទីគួរឱ្យសប្បាយណាស់ គេក៏នាំគ្នាឈប់សំរាកបរិភោគអាហារ លុះយប់វេលាណាគេក៏នាំគ្នាដេកអស់ ។ លុះដល់ពាក់កណ្ដាលអធ្រាត្រស្រាប់តែមានហ្វូងដំរីព្រៃចុះមកផឹកទឹកបឹងនោះ ។ ដំរីព្រៃកាលបើឃើញដំរីដែលនៅក្នុងក្បួននោះ ក៏កើតសេចក្ដីស្អប់ដោយឃើញជាតិខ្លួននៅជាខ្ញុំគេដូច្នោះ វាចង់សម្លាប់បំផ្លាញចោល ក៏ស្ទុះបោលសន្ធឹងពីចម្ងាយជាន់ពួកឈ្មួញៗដែលស្រែកយំលាន់ទ្រហឹងហើយក៏ខំស្ទុះរត់ពួន ប៉ុន្តែទៅជាបែរមុខទៅរកដំរីព្រៃៗ វាចាក់នឹងភ្លុកបោកនឹងប្រមោយ ជាន់នឹងជើងវាទាំងអស់ ។ មានមនុស្សទទួលគ្រោះថ្នាក់ដល់ស្លាប់ជាច្រើន ក្នុងពេលយប់នោះ ។

ព្រលឹមឡើង អ្នកដែលបានរួចរស់ជីវិតនាំគ្នាយំទ្រហឹង ដោយបានឃើញការអន្តរាយគួរស្ញើបយ៉ាងដូចនេះ ហើយក៏នាំគ្នាតូចចិត្តនឹងព្រះនាងទមយន្តី ថាចង្រៃមកពីព្រះនាង ព្រោះព្រះនាងជាស្រីកាឡកណ្ណី ដែលអាទិទេពដាក់ទណ្ឌកម្មដោយមិនដឹងជាធ្វើអ្វីខុសយ៉ាងធំ ហេតុដូច្នេះហើយបានជាពៀរនោះ ជួនទៅដល់អ្នកឯណាដែលជួយយកអាសាព្រះនាង ។ ព្រះនាងឮសូរពួកឈ្មួញកំណាចពោលពាក្យដូច្នោះ ក៏ថយទៅឆ្ងាយ មានទឹកព្រះនេត្រដោរដេលសស្រាក់ ហើយនឹកចឹងនឹងខ្លួនឯងថា: "ពួកឈ្មួញនិយាយត្រូវមែន ព្រោះអាទិទេពចឹងតែទឹងរូបអញមួយ ពីថ្ងៃនេះទៅ អញលែងស្គាល់សេចក្តីសុខទៀតហើយ, ប្រហែលជាអញបានធ្វើអ្វីអាក្រក់ពីជាតិមុន បានជាអញវេទនាគ្មានស្រាកស្រាន្តយ៉ាងនេះ, ប្តីអញអន្តរាយប្រទេសហើយរត់ចោលអញថែមទៀត ឥឡូវនេះ អញធ្វើឲ្យស្លាប់មនុស្ស ដែលជួយយកអាសាអញទៀត, ឱបុះទោសអ្វីអាក្រក់យ៉ាងនេះ! ម្តេចបានជាដីរនោះមិនព្រចអញ? មែនហើយពាក្យចាស់លោកថា "អាយុមិនអស់ មិនស្លាប់" បើដូច្នោះអញមិនទាន់អស់អាយុទេ ពីព្រោះដីរមិនព្រចអញ ។ តើអាទិទេពធ្វើទណ្ឌកម្ម ដោយអញរើសយកព្រះបាទនល:ជាស្វាមីទេឬ? ពុទ្ធោអើយកម្មអ្វីក៏កាចយ៉ាងនេះ" ។

(មានត)

ដំណឹងតាមខ្យល់ក្នុងកន្តារៈ

# លោកផេង-ជ្រើវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ប្អូនកាលនាងច្រៀងថា: ស្នេហានៃស្ត្រីទុកដូចជាមួយដើមត្នោតក្នុងវាលខ្សាច់, ស្នេហានៃបុរសទុកដូចជាខ្យល់កំបុតត្បូងដែលមានអំណាចអាចបំបាក់ដើមត្នោតនោះ ដើម្បីធ្វើមួយឲ្យស្ថិតនៅទីតែមួយកន្លែង ។

ឱមាសព្រលឹងបង! អូនដែលសម្រាកនៅផ្ទះ អូនមិនរលឹកដល់សួនរហោស្ថានដែលបងធ្លាប់នាំអូនទៅលេងទេឬ? គឺជាសួនដែលតាំងនៅត្រង់ចន្លោះកំពែងយ៉ាងខ្ពស់ សូម្បីចុងឈើក៏ខ្ពស់មិនដល់ គឺជាសួនដែលគេបង្កប់ក្នុងកំពែងសដូចកែវចរណៃក្នុងផ្កាចម្ប៉ា ។

ឱ មាសស្នេហ៍! អូនមិនរលឹកដល់ពេលព្រហាមត្រជាក់ដែលអូនបណ្ដោយដួងព្រលឹងឲ្យទោរទន់បុះតាមចំណង់កាមរាគរបស់បង ដូចជាដើមត្នោតទោរបុះតាមអំណាចកម្លាំងខ្យល់ ឬទេ? ។

ឱដើមត្នោតដ៏វែងមាសបងអើយ បងសូមឲ្យដីខ្សាច់ដែលធ្វើជាផ្ទះសង្កត់ពីលើរូបអូន មានទម្ងន់យ៉ាងស្រាល ។

ប្អូនកាលនាងច្រៀងដូច្នេះវិញថា:

សូមឲ្យខ្លួនបងជិតជាប់នៅនឹងដួងវិញ្ញាណអូនជានិច្ច ។

ត្របកភ្នែកអូនដូចជាស្រទាប់ផ្កាព្រលិតពីរដែលស្វិតដោយកំដៅថ្ងៃក្នុងគិម្ហរដូវ ចំណែកបបូរមាត់អូននៅក្រហមឆ្អិលដូចផ្លែទន្ទាប់ទុំ ។

បងសុំផ្ញើជីវិតលើប្បូរហើយ សក់អូនផាត់ធ្លាក់មកគ្របលើថ្ងាសអូនដូចជាត្រចៀកកាំទំពើហើបក្ដុក ហើយទឹកថាក្ដុកដែលឡើងសម្បូរដូច្នេះប្រែហាលដូចជាថ្ពាល់អូន ឬទេ? ។

ផ្កាព្រលិតរញមហើយ ហេតុអ្វីក៏អូននៅក្រឡេកមើលបងទៀត?

ត្រចៀកកាំហើរទៅបាត់ហើយ ហេតុអ្វីក៏អូនចាំផាត់សក់ចេញ?

ផ្លែទន្ទាប់ហែកបែកអស់ហើយ ហេតុអ្វីក៏អូននៅញញឹមដាក់បងទៀត? ។

ឬនាងប្រៀនដូច្នេះវិញថា:

ព្រាបសទំដេកលើដើមគគីរវេលាយប់ ៗ មុនដំបូង វាហើរព័ទ្ធចុះឡើងជុំវិញដើមឈើនេះ ប៉ែបញញើតញញើមពុំហានចូលដេកឥឡូវនេះ វាហើរមកដេកកល់យប់លើចុងមែកដែលខ្ពស់ជាងគេ ។

លលកគោរវើឡើយ ៗ រកគូហ ...

ចំណែកបង ៗ សូមប្រៀនបំពេអូនដោយបិយវាចា ។ បងជឿថាព្រាបសទីងនាងនារីតែងមានចិត្តដូចគ្នា សម្រាប់នាំខ្លួនទៅរកសួនច្បារដែលលលកធ្លាប់គោរវ ។

ឬនាងប្រៀនដូច្នេះវិញក៏មាន:

កាលណាអូនបង់សំដែងកាយសញ្ញាឲ្យបងឃើញ អូនលូកដៃចេញមកខាងក្រៅបង្អួចតាមចម្រឹងដែក ៗ ឃើញដូច្នោះព្រលឹងបងស្ទុតបាត់មិនដឹងជាទៅណា ៗ

ផ្កាចម្ប៉ី ថាមានពណ៌សហើយ ទឹកកកនៅលើភ្នំ ថាទុកជាសក្តិហើយ, ចង្កៃកក៏សរលើងហើយ, ផ្កាម្លិះក៏សស្អាតហើយ, ប៉ុន្តែគង់នៅមិនសស្មើនឹងម្រាមដៃអូនដែលប្រកបដោយក្រចកក្រហមទុំដូចផ្លែជម្ពូ ៗ

បងតែងនិយាយប្រាប់មិត្តភក្តិរបស់បង ដែលចេះតែឆ្ងល់នឹងធំក្លិនក្រអូបឈ្ងុយថា: ដៃអូនទើបនឹងលូកចេញមកក្រៅបង្អួចអម្បាញ់មិញ ផ្លូវបំបែកត្រង់ហ្នឹងបានជាធំក្លិនក្រអូប ព្រោះក្លិនក្រចកអូនសែផ្សាយមក ៗ

ចំណែកនាងឡាឡា មានបំណងថា: អារម្មណ៍ក្នុងជីវភាពឥតមានអាក់អន់ឡើយ ៗ ប៉ុន្តែ នាងតែងរក្សាទូរស្រមោលមុខព្រះអង្គម្ចាស់អ៊ុស្មាអ៊ុលដែលនាងបានជួបមួយភ្លែត ទុកនៅក្តៅ ៗ ក្នុងដួងព្រលឹង ហើយរឿងនេះនាំឲ្យនាងសប្បាយជានិច្ច ៗ នាងមានសេចក្តីសង្ឃឹមទុកថា គង់ថ្ងៃណាមួយនាងនឹងបានជួបជាមិនខាន, ម្ល៉ោះហើយនាងគិតតែពីធ្វើការងារនៅក្បែរម្តាយនឹងស្រី ក្នុងគណៈអ្នកបកបរក៏ ឥតមានរវល់អំពីប្រុសណាឡើយ ៗ នាងបណ្តោយតាមតែអ្នកដែលស្រឡាញ់ពប់អានគេសរសើរហើយត្រង់ខ្លួនបំរុងនឹងប៉ះទៅលើសេចក្តីទុក្ខយ៉ាងធ្ងន់ក៏មិនដឹង ៗ

ព្រឹកមួយ គឺជាថ្ងៃទី ៤ នៃការសំចតអាស្រ័យនៃអ្នកបកបរក៏ នាងតាដក្រាជាម្តាយហៅកូនទាំងពីរមកប្រាប់ថា:

- បើកូននាំហ្វូងពពែយកទៅឲ្យស៊ីស្មៅ នាពេលខាងនាយជ្រោះឯណោះបានឬទេ? ព្រោះនៅកន្លែងនេះស្មៅក្រហើយសុទ្ធតែថ្មៗ ទុកសម្រាប់ឲ្យអូដ្ឋស៊ីស្ទើរមិនគ្រប់គ្រាន់ផង ។

ឡូឡានិងអាត់ស្សាតា ដល់ថ្ងៃប្អូនត្រង់ ក៏នាំគ្នាកៀងពពែចេញទៅ ។ គឺជាថ្ងៃក្តៅគិម្ហរដូវដែលអាកាសនិងមេឃឡើងពណ៌ខៀវថ្លា ។ នាងទារិកាពីរនាក់បងប្អូន នាំគ្នាទៅរកជ្រកម្លប់ឈើដែលដុះល្បោះៗ ។ នាងចំប្រក់ឡើងទួលពលខ្ពង់ទួលកំពូលមួយ ដុះសុទ្ធតែដើមឈើ ហើយអាចមើលឃើញនូវកន្លែងសំណាក់ដែលតាំងនៅខាងក្រោម ទៀបជើងភ្នំបានដោយងាយ ។ នាងឡើងតាមច្រកមួយយ៉ាងចង្អៀត ចំប្រះប្រក់ទម្រាំបានដល់ខ្នងខាងលើ ។

នៅទីនោះ ម្លប់ត្រជាក់ស្រេង ក្រោមស្លឹកត្នោតក្រញ៉ាងៗ ពពែស៊ីស្មៅក្បែរគល់ត្នោត ។ អាត់ស្សាតា អស់កម្លាំងពេកក៏អង្គុយចុះហើយសូត្រធម៌ក្បូរដ៏ធំៗ តែម្នាក់ឯង ដើម្បីសម្រាលសេចក្តីទុក្ខដែលមាននៅក្នុងចិត្ត ។ ចំណែកឡូឡាសំឡឹងមើលអច្ឆរិយទស្សនាដែលកើតមានដល់ចក្ខុបសាទនៃនាង ។

ត្រង់កន្លែងដែលនាងជ្រក គេអាចមើលឃើញដីទំនាបទាំងមូលនឹងដីទំនាបច្រកភ្នំទាំងអស់ ឥតមានសល់ត្រង់ណា ។ ដីពណ៌ពព្លក់ត្រូវស្មៅព្រះអាទិត្យចាំងរន្ទះស្ទើរស្រវាំងភ្នែក ។ រឿងហេតុអ្វីទាំងប៉ុន្មានដែលមាននៅក្នុងទីពល សូម្បីបន្តិចបន្តួច ក៏មិនផុតពីភ្នែកនាងឡូឡា ។

នាងក្រមុំមើលឃើញស្រែៗ ស្មៀកសំពត់ស៊ើងៗ នឹងប្រុសៗស្លៀកពាក់សំពត់ស៊ីទ្រូ រញាក់រញាល់ រត់ទៅរត់មក ចេញចូលក្នុងជំរំសំពត់ ។ នាងឮស្ករសន្ធឹកអ៊ូអរ តាមខ្យល់បក់មក ។ គឺជាជីវភាពដែលប្រព្រឹត្តទៅ ក្រលៃថ្ងៃនៃពួកមនុស្ស ព្រមទាំងមុខរបរផ្សេងៗ ទាំងសំដីប្រុសៗនិយាយគ្នាចំរៀងស្រីៗ សម្រែកកូនក្មេង សូរត្រៃព្រស នឹងសំឡេងសត្វអូដ្ឋ ។

នាងឡីឡា ស្រាប់តែស្រែកដូចគេភ្ញាក់ ។ នាងក្រឡេកទៅឃើញសុទ្ធតែទាហានជិះសេះហុយដីទ្រលោមដូចពពក បរសំដៅជំរំសំណាក់អាស្រ័យ ។ នាងស្គាល់ជាក់ជាទាហានសេះសាសន៍តួគី ព្រោះនាងសំគាល់សំលៀកបំពាក់បាន ។

គ្រឿងសញ្ញារុចគ្រវីវន្ទះថៃចាំងសស្កុច ។ នាងនឹកដល់កាលនាងទៅពីក្មេងមានបោះបូនដូចេះម្ដង; រឿងដែលប្រកបដោយសេចក្ដីទុក្ខព្រួយ នឹងដោយសេចក្ដីវិនាសនេះ តែនឹកដល់ ទាំងតែងញាក់ដូចគេគ្រន ។

ពួកតួគីតែមកហើយ មិនដែលឲ្យសេចក្ដីចំរើនទេ មានតែធ្វើឲ្យអន្តរាយគ្រប់យ៉ាង ប្លន់ដណ្ដើមយកសម្បត្តិទ្រព្យ ។

នាងដើរទាំងញ័របួលទៅជិតអាតស្បាតា និយាយប្រាប់ថា: នៃអ្នកបង! ពួកទាហានសេះតួគី ចូលទៅកន្លែងសំណាក់យើងហើយ ។

នាងអាតស្បាតា ដែលមិនអាចអត់ទ្រាំនឹងការភ័យបាន ក៏ប្រាប់ប្អូនថា: ឡីឡាមាសបង! រត់យើង! ត្រូវយើងរត់! ។ នាងឡីឡាចាប់

ទាញបងមកនឹងទ្រូងហើយ ឆ្លើយថា: ចុះម៉ែយើងយ៉ាងម៉េចទៅហ្ន៎! ។ ចំណែកអាឥស្សរាតាញ័រទទ្រើកដូចកូនសត្វ ។

ក្នុងខណៈនោះ គេឮស្នូរបាញ់កាំភ្លើង ៗ ពួកទាហានសេះបរសេះលុកលុយក្នុងទីសំណាក់ ជាន់ស្រីៗ នឹងក្មេងៗ ដួលប្រផាប់ប្រផិល ។

នាងនារីមើលឃើញនូវពួកមនុស្សរត់ឈូចុះឈូឡើង ហើយនាំគ្នាឈរផ្តុំនៅកណ្តាលទីសំណាក់ ហើយឃើញម្នាក់ទៀតដូចជាមេគេដើរឃ្លាតចេញពីពួកអ្នកអស់នោះចម្ងាយពីរបីម៉ែត្រ ។

ខណៈនោះ នាងឡីឡាឃើញលោកតាម៉ាព្រុកអែលគាឌី ដើរទៅរកអ្នកនោះ ។ តាមពិត នាងស្តាប់មិនឮសំដីនិយាយទេ ប៉ុន្តែបើតាមអាការនៃលោកតានោះ នាងយល់ថានឹងមានសេចក្តីទុក្ខដល់អ្នកចពចរក៏ជាថ្មីទៀត ។

លោកតាម៉ាព្រុកអែលគាឌី ដូចជាជជែកតវ៉ាយ៉ាងខ្លាំង តែមេទ័ពតួគីដកយកក្រដាសមួយសន្លឹកយ៉ាងធំ ពីកាបូបស្បែកព្យួរនៅនឹងកែបសេះ ហើយហុចទៅឲ្យលោកតាម៉ាព្រុកៗ ឃើញដូច្នោះ ក៏លើកដៃទាំងពីរទៅលើដោយអាការស្លុតត្រង់ តែមេទ័ពតួគីមិនយល់ព្រមតាម ។

ក្នុងពេលនោះ មេទ័ពតួគីបង្គាប់ឲ្យទាហានខ្លះលោតចុះពីសេះរត់ចូលទៅឆែកក្នុងជំរំ ហើយប្រហែលមួយស្របក់ ស្រាប់តែឃើញបានកាំភ្លើងព្រមទាំងគ្រាប់រំសេវ ដែលជាអាវុធរបស់អ្នកដើរទេសក៍ធ្វើទុកសម្រាប់ការពារចោរ ។

លុះឃើញដូច្នោះ មេទ័ពតួគីបង្គាប់ឲ្យលើកជំរំចេញទៅភ្លាម កុំបង្អង់ ។ ត្រង់ហ្នឹងហើយ គឺជាពេលអុកឡុកយ៉ាងខ្លាំងដែលសូរស័ព្ទលាន់ឮមកដល់ត្រចៀកនាងនារីបងប្អូនទាំងពីរ ។ នាងឡូឡាឃើញម្ដាយរបស់នាងមានទាហានតួគីបណ្ដើរមុខក្រោយ ។ នាងនេះព្រួយពេក ដូចជាបាត់ស្មារតី ដើរទាំងមិនដឹងខ្លួននៅកណ្ដាលទាហានពីរនាក់ ។

ក្នុងពេលនោះ ឡូឡាដឹងថា ម្ដាយរបស់នាងត្រូវការនឹងចង់ដឹងឲ្យច្បាស់ថា ត្រូវឲ្យកូនស្រីគាត់ទាំងពីររូបគ្រោះថ្នាក់ជាជាងលុះក្នុងកណ្ដាប់ដៃតួគី ប៉ុន្តែចំណែករូបនាងយល់ឃើញដូច្នេះវិញ: សេចក្ដីទុក្ខដោយដាច់ជាល្ហើយ បើបែងចែកគ្នារវាងសត្វកំសត់បីនាក់ដែលមានសេចក្ដីស្នេហាចំពោះគ្នានឹងគ្នា គឺជាសេចក្ដីទុក្ខស្រាលបន្តិចជាជាងការបែកនឹងការបាត់មុខចេញពីគ្នា ។

គិតដូច្នេះហើយ ឡូឡាមិនអាចញុំាងសន្ដានប្រកបដោយសេចក្ដីតក់ស្លុតឥតឧបមា សេចក្ដីទុក្ខយ៉ាងធ្ងន់ ឲ្យតាំងស្ងៀមបានក្នុងដួងហឫទ័យ ព្រោះគិតឃើញថានាងនឹងត្រូវព្រាត់ប្រាសចាកមាតាជាទីស្រឡាញ់ ។ ប៉ុន្តែ តើនាងក្រមុំអាចទប់ទល់នឹងព្រេងវាសនាបានឬទេ? ចំណែកអាតស្សាតានេះ ក៏ថ្ងូរថាហើយថាទៀតទាំងយំផងថា "នែឡូឡា! ត្រូវយើងរត់! បងខ្លាចណាស់! បងមិនចង់ឲ្យគេចាប់យើងបានឡើយ!" ។

នានឡើឡាឈរកៀកទឹងបងស្រី មើលតាមបំណាំងព្រះអាទិត្យ ពេលព្រលប់ឃើញពួកអ្នកដើរទេសទាំងប៉ុន្មានកំពុងតែរើជុំ បញ្ចុក ស្បៀងអាហារក្នុងហិប ហើយប្រញាប់ប្រញាល់ធ្វើតាមបង្គាប់នាយកង តួគីដែលប្រាប់ឲ្យលើកទីកន្លែង ។

ត្រូវដឹងថាសម័យនោះ មិនដូចសម័យឥឡូវនេះឡើយ គឺក្រុង ទីប៉ូលីតែន មិនមែនតាំងនៅក្នុងអាណាព្យាបាលនៃសាសន៍ អ៊ីតាលីទេ ។

គេដឹងប្រាកដថា គឺសាសន៍អារ៉ាប់ដែលបានរុករានទន្ទ្រានជាច្រើន លើកច្រើនគ្រា ក៏សម្រេចយកក្រុងនេះបានជាស្រុកអាណានិគមរបស់ ខ្លួនក្នុងសតវត្សទី ១១ ប៉ុន្តែសាសន៍នេះមិនអាចទប់ទល់នឹងការរំលោក នៃសាសន៍ទួរគីបាន ក៏ត្រូវឡប់ប្រគល់ស្រុកបំណុះនេះឲ្យទៅពួកកងទាហាននៃក្រុងកុងស្តង់ទីណុបវិញ ។

លុះដណ្តើមស្រុកនេះបានមកពីដៃអារ៉ាប់កាលណា សាសន៍ទួរគី ក៏ចាប់ធ្វើការមានប្រយោជន៍យ៉ាងធំនៅទីក្រុងទីប៉ូលីតែនភ្លាម ឥតបង្អង់ ព្រោះក្រុងនេះជាមានច្រកតែមួយ ជាសំណល់សម្រាប់ឲ្យគេធ្វើការរំលាយ សាសនា បញ្ចូលទៅជាមួយនឹងពួកជាតិមហាម័តប្រទេសអាហ្វ្រិក ។

គេដឹងថា ការរំលាយបញ្ចូលសាសនារវាងក្រុងកុងស្តង់ទីណុបនឹង ក្រុងទីប៉ូលីតែន អាចជំនួសសិទ្ធិនយោបាយ ព្រមទាំងបង្កើតស្ពានមេត្រី ឲ្យកាន់តែមាំពូកែឡើង ។ (មានត)

# ពិធីឈាបនកិច្ច

## សពព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

ទុកញាំ ម្ហូង-ឃួន ក្រុមការដើមខ្សែលេខ ១

ក្រសួងពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

រៀបរៀង

---

ព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង ធ្វើអធិបតីរងក្រុមជំនុំព្រះត្រៃបិដក ក្នុងចំណោមព្រះសង្គីតិកាចារ្យទាំងឡាយនៃពុទ្ធសាសនបណ្ឌិត្យ ជាអ្នកយកចិត្តទុកដាក់ផ្ចិតផ្ចង់ធ្វើការងារប្រែពិនិត្យព្រះត្រៃបិដក ឥតខ្លាចនឿយហត់ ដល់មកថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៤៦ ចាប់អាពាធជាទម្ងន់ដោយរោគឡើងឈាមស្ទឹក ស្រពន់ញ័រព្រះហស្តខ្វិនមួយចំហៀងខ្លួន បាននិមន្តទៅព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលាភ្នំពេញជាយូរខែ ក៏គ្រាន់តែបានធូរបន្តិចៗ ។

លុះកន្លងមកបាន ៧ ឆ្នាំ រោគនោះបណ្ដាលឡើងម្ដងទៀត ពួកសក្យានុសិស្សទាំងក្រុមញាតិ បានរកថ្នាំពេទ្យកែមិនបាត់ ។ រោគគាត់តែរឹតខ្លាំងឡើងៗ រាល់ថ្ងៃ មិនបានធូរថយសោះ ។ លោកក៏ដឹងច្បាស់ថា ខ្លួនលោកមិនជាទេ ក៏សុំលាចេញចាកដំណែងអធិបតីរងក្រុមជំនុំព្រះត្រៃបិដក ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ដល់មកថ្ងៃទី ២៨ ខែឧសភាឆ្នាំ ១៩៥៤ ពេលនោះរោគរឹតតែខ្លាំងឡើងហួសវិស័យពេទ្យព្យាបាល មច្ចុរាជក៏ចូលមកផ្តាច់ជីវិតិន្ទ្រិយ នៃព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង ក្នុងថ្ងៃចន្ទ ១៥ រោច ខែពិសាខ ឆ្នាំមមីឆស័ក ពេលម៉ោង ៣ ទៀង ១៥ នាទី រំលងអាធ្រាត្រ ត្រូវនឹងថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ១៩៥៤ ក្នុងជន្មាយុគំរប់ ៦២ ឆ្នាំ នៅកុដិរបស់លោក ។

សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ទាំងព្រះរាជាគណៈទាំងឡាយ ព្រមទាំងពួកសិស្សានុសិស្ស ហើយនិងក្រុមញាតិបានធ្វើពិធីស្រង់ទឹកសពរួច បានលើកសពដំកល់ក្នុងក្តារមឈូស ដែលរចនាដោយក្បាច់រំលេចពណ៌ផ្សេងៗ ហើយនាំសពចេញពីកុដិរបស់លោកទៅដំកល់លើបញ្ចា ៣ ជាន់ក្នុងសាលាបិណ្ឌ ដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃ រហូតដល់ថ្ងៃ ៣ កើត ខែជេស្ឋ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ១៩៥៤ វេលាម៉ោង ១៥ បានរៀបពិធីកិលសពដំកល់លើរថយន្ត ដែលរចនាដោយក្បាច់ផ្កាផ្សេងៗ ហែសពចេញតាមផ្លូវទៅខាងលិចវត្ត តម្រង់ទៅខាងត្បូងតាមវិថីប៉ូបែរ រួចបកទៅតាមតិវិថីឡេងស៊ីស៊ីវត្ត ព័ទ្ធទៅកាន់ទីសុសានដ្ឋានមុខវត្តបទុមវតី ដល់ហើយលើកដង្ហែសពដំកល់ក្នុងបារាំយ៉តព្រះរាជទ្រព្យ ដែលតាក់តែងដោយក្បាច់រចនាផ្សេងៗ ។

ក្នុងចំណោមឥស្សរជន ដែលអញ្ជើញទៅកាន់ពិធីបុណ្យគេសង្កេតឃើញ ឯ.ឧ.ជូ-ព្រឿង រដ្ឋមន្ត្រីក្រសួងធម្មការ ឯ ឧ.ក៉យ-លុត ឯ ឧ.សម-ញាណ នាយកមន្ទីរ នាយក្រមនិងពួកពុទ្ធបរិស័ទជាច្រើន ។

ឯចំណែកព្រះសង្ឃមានសម្តេចព្រះសុធម្មាធិបតី អ៊ុង-ស្រី សង្ឃ-នាយកគណធម្មយុត្តិ, ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ព្រះអរិយកស្សប អ៊ុច ព្រះរាជាគណនិងឋានានុក្រមហើយនិងភិក្ខុសាមណេរជាច្រើន បានមកជួបជុំជាឧឡារិក ។

ម៉ោង១៧ លោកគ្រូមហា ប៉ាង-ខាត់ សមាជិកក្រុមជំនុំព្រះត្រៃបិដក តំណាងក្រុមពុទ្ធសាសនបណ្ឌិត្យ បានសូត្រសុន្ទរកថាមួយពណ៌-នាសរសើរកិត្តិគុណ ព្រមទាំងសេចក្តីសោកស្តាយចំពោះសពព្រះអមក-ភិរក្ខិត អ៊ុយ-ប៉ាង ដូចតទៅនេះ

សូមក្រាបទូលសម្តេច ! ព្រះតេជព្រះគុណ !

សូមជំរាបឯកឧត្តម ! លោកសប្បុរសទាំងឡាយ !

ព្រះថេរៈដែលខ្ញុំព្រះករុណាអាត្មាភាព និងពោលសរសើរកិត្តិគុណព្រមទាំងរៀបរាប់សេចក្តីសោកស្តាយនេះ កាលពីលោកមានជន្មាយុនៅឡើយ លោកធ្លាប់វិស្សាស័កដោយមេត្រីភាពជាមួយនឹងយើង, ឥឡូវនេះអង្គលោកជានាមធម៌នោះនិមន្តទៅបាត់ហើយ នៅសល់តែរូបធម៌ស្តុកស្តឹងនឹងថ្កល់លែងមានពុទ្ធដីកាតបតនឹងយើងទៀត ។ មរណកាលអង្គ

លោកនេះ នាំឲ្យយើងខ្ញុំទាំងឡាយសង្វេគតក់ស្លុត ព្រមទាំងសោកស្ដាយអង្គលោកជាបំផុតមិនដឹងធ្វើដូចម្ដេច ព្រោះជាធម្មតាដែលផុតវិស័យមនុស្សលោកនឹងការពារបាន ទើបយើងខ្ញុំទាំងឡាយបបួលគ្នាមកគោរពសពអង្គលោកក្នុងពេលបច្ឆិមទស្សន៍នេះ មានចិត្តពោរពេញដោយវិប្បយោគទុក្ខ ។

ព្រះតេជព្រះគុណ ព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង ជាក្រុមជំនុំព្រះត្រៃបិដកមួយរូប លោកចូលធ្វើការកាលពីថ្ងៃទី ២៨ ឆ្នាំ ១៩៣១ លោកមានគុណសម្បត្តិសមត្ថភាពបរិបូណ៌ ក្នុងកិច្ចការរបស់ក្រុមជំនុំព្រះត្រៃបិដក ដោយការស្ទាត់ជំនាញនិងយកព្រះទ័យទុកដាក់ក្នុងកិច្ចការរបស់ខ្លួនគួរសរសើរ ។ ហេតុនេះ ទើបព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានគ្រឿងឥស្សរិយយស (មេដៃយ៍) មុណីសារភ័ណ្ឌ នៅថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៩ ។ មិនតែប៉ុណ្ណោះទេ លុះដល់មកថ្ងៃទី ១ កុម្ភៈ ១៩៤៤ ព្រះករុណាជាម្ចាស់ជីវិត ទ្រង់ព្រះមេត្តាប្រោសតែងតាំងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដកទៀត ដើម្បីឲ្យសមតាមគុណសម្បត្តិសមត្ថភាពរបស់អង្គលោក ។

ដោយធ្លាប់នៅរួមធ្វើការជាមួយគ្នាអស់កាលយូរ យើងខ្ញុំទាំងអស់គ្នាបានស្គាល់ព្រះថេរៈអង្គនេះច្បាស់លាស់ណាស់ អង្គលោកជាអធិបតី

វង្សត្រកូលជាសន្តិភាពមួយអង្គដ៏ប្រសើរ គួរកប់ថាជាអ្នកប្រាជ្ញមួយអង្គ ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយក្នុងព្រះពុទ្ធសាសនា មានសណ្ដាប់ធ្នាប់សុភាពរាបសា មានព្រះទ័យទន់ភ្លន់ស្រឡាញ់រាប់អានសហការីទាំងឡាយគ្រប់គ្នាមិនរើសមុខ មានវាចាពីរោះគួរជាទីរីករាយ មានពុទ្ធដីកាទៅកាន់លោកអង្គណា ឬលោកណាមួយ តែងតែនាំយកមេត្តាចិត្តទៅផ្សំជាមួយផង នាំឲ្យសហការីទាំងឡាយស្រឡាញ់ពេញចិត្តរាប់អានហើយគោរពអង្គលោក ។

ពេលនេះ ព្រះតេជព្រះគុណ ព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង ដែលយើងខ្ញុំបានពោលសរសើរកិត្តិគុណមកនេះ ផុតកិច្ចនឹងរស់នៅទៅទៀតបានហើយ លោកនិមន្តទៅកាន់បរលោកហើយ នាំយកទាំងសេចក្ដីល្អទៅជាមួយអង្គលោកផង ទុកនៅសល់តែសពអង្គលោកនិងការងាររបស់លោក ជានិមិត្តរូបដែលមិនចេះស្លាប់ ។ ព្រះតេជព្រះគុណ ព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាងនេះ លោកបានយកជីវិតអង្គលោកទៅរួមនៅក្នុងការប្រសើរនេះ ដែលជាការមិនចេះស្លាប់ បំណាច់បានជាកើតមកហើយមានជីវិតរស់នៅ ត្រូវធ្វើការឲ្យប្រសើរយ៉ាងនេះ សឹមស្លាប់ទៅវិញ គឺកើតមកហើយត្រូវយកល្អឲ្យបាន ។ ដូច្នេះហើយ បានជាអ្នកប្រាជ្ញទាំងឡាយពោលទុកថា: "ស៊ូស្លាប់ទៅជា រស់ធម៌កុំបីបង់" ។

ព្រះតេជព្រះគុណ !

ពេលនេះ យើងមកជួបជុំគ្នាពោលសរសើរកិត្តិគុណព្រះតេជព្រះគុណ ពណ៌នារៀបរាប់សេចក្ដីសោកស្ដាយ ពោលហើយពោលទៀតស្ទើរតែមិនអស់មិនហើយ ដោយសេចក្ដីស្រណោះអាឡោះអាល័យជាទីបំផុត ៗ ព្រះតេជព្រះគុណនិមន្តទៅក៏ពិតមែន តែសេចក្ដីល្អរបស់ព្រះតេជព្រះគុណឋិតនៅក្នុងដួងចិត្តយើងខ្ញុំគ្រប់គ្នាមិនភ្លេច ៗ យើងខ្ញុំជឿជាក់ថា ៈ ព្រះតេជព្រះគុណគង់មិនភ្លេចការងារព្រះត្រៃបិដកនេះទេ ៗ នៅប្រទេសកាន់ពុទ្ធសាសនា គេតែងបានស្គាល់កិច្ចការយើងប្រាកដណាស់ ; ពេលនេះទៀត, នៅប្រទេសភូមាព្រះមហាថេរានុត្ថេរៈទាំងអស់ក្នុងសកលលោក មកប្រជុំធ្វើឆដ្ឋសង្គាយនានៅក្រុងរង្គូន ព្រះសង្ឃិកាចារ្យទាំងអស់អង្គនេះ បានទទួលស្គាល់ព្រះត្រៃបិដកយើង គេយកព្រះត្រៃបិដកយើងជាគោល ជាមេបែបបទ ក្នុងការសង្គាយនាទី ៦ នេះ ៗ ដូច្នោះ! ការងារយើងជាការដ៏ប្រសើរបំផុត បានទុកស្នាព្រះហស្ដជាក់ស្ដែងស្រាប់ ៗ ពេលថ្ងៃ ព្រះតេជព្រះគុណគង់សរសេរ គង់ពិនិត្យ, ង់ជញ្ជឹងគិត ទាំងអស់នេះ ធ្លាក់ជាប់នៅក្នុងក្រដាស គឺព្រះត្រៃបិដកយើងនេះ, ព្រះតេជព្រះគុណ មុខជានឹងយកសេចក្ដីល្អនេះជាប់ទៅជាមួយព្រះអង្គផង ហើយនិមន្តទៅកើតក្នុងទិព្វវិមាននាទេវបុរី ៗ យើងខ្ញុំទាំងអស់គ្នា នៅខាងក្រោយនេះតែងបន្តកិច្ចការដ៏ប្រ-

សើរនេះតទៅទៀត រហូតដល់ទីបំផុត ។ អំណើះតទៅ យើងខ្ញុំទាំងអស់គ្នាមានតែសេចក្ដីអាឡោះអាល័យនឹងសេចក្ដីសោកស្ដាយមិនភ្លេច ។

យើងខ្ញុំទាំងអស់ពោរពេញដោយទុក្ខ សូមប្រមូលបុញ្ញរាសីនៃយើងខ្ញុំគ្រប់គ្នាលើកលើសិរសា ដម្កល់ទុកជាធម្មបណ្ណាការដ៏ខ្ពង់ខ្ពស់ ឧទ្ទិសប្រគេនព្រះតេជព្រះគុណ សូមព្រះតេជព្រះគុណទទួលយកដោយរីករាយ ហើយសូមឲ្យបានសម្រេចជាបត្តានុមោទនាមយៈ សូមឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលវិបុលសុខសិរីសួស្ដីជយមង្គលតរៀងទៅ ! ។

ទីបំផុត, យើងខ្ញុំទាំងឡាយ សូមខមាទោស ចំពោះព្រះតេជព្រះគុណ សេចក្ដីទាំឆ្គងលើសលោះដោយកាយវាចាចិត្តក្ដីណា សូមព្រះតេជព្រះគុណអភ័យទោសដោយការុញ្ញភាពឲ្យទាន ។

*
* *

បន្ទាប់មក ព្រះអរិយកស្សប អ៊ូច បានថ្លែងសុន្ទរកថាពណ៌នាពីប្រវត្តិរូបនិងគុណសម្បត្តិ នៃសពព្រះអមរកិត្តិ អ៊ុយ-ប៉ាង ដូចមានសេចក្ដីសង្ខេបតទៅ ៖

ព្រះអមរកិត្តិ ( អ៊ុយ - ប៉ាង ) កំណើតនៅភូមិកំពង់ចិនត្បូងឃុំវិញដាំង ខែត្រក្រមួនស បិតានាម អ៊ុយ មាតានាម អាត់ សម្ភពនៅឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៥ ។ កាលនៅពីកុមារបានអាយុ ១៧ ឆ្នាំ បិតានាំកុមារ អ៊ុយ-ប៉ាង នេះ ឲ្យទៅនៅសិក្សាអក្សរសាស្ត្រ និងលោក

គ្រូ ស៊ីម ជាចៅអធិការវត្តចាស់ស្ដៅគណៈធម្មយុត្តិ ខេត្របាក់ប៉ក្នុង
ដែនកូសាំងស៊ីន ។ លុះកុមារ អ៊ុយ-ប៉ាង រៀនសូត្របានចេះដឹងគួរសម
ហើយ លោកគ្រូ ស៊ីម ក៏ឲ្យបព្វជ្ជាជាសាមណេរនៅវត្តនោះបានមួយ
ព្រះវស្សា ។ មានឧបាសកម្នាក់នាម ខឹម-ទិត នៅក្រុងភ្នំពេញធ្លាប់បាន
បព្វជ្ជាសិក្សាក្នុងសំណាក់សម្ដេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្ម-
យុត្តិ វត្តបទុមវតី ស្រុកកំណើតនៅខេត្រក្រមួនសដៅ បានទៅជួបនឹង
សាមណេរ អ៊ុយ-ប៉ាង បានទូលរៀបរាប់អំពីលទ្ធិព្រះពុទ្ធសាសនា
ប្រាប់សាមណេរ អ៊ុយ-ប៉ាងៗ មានចិត្តជ្រះថ្លាចង់ចេះដឹង ទើបសុំអនុញ្ញាត
ពីលោកគ្រូ តាមឧបាសកទិតមកនៅភ្នំពេញ ។ ឧបាសកនេះបាននាំ
យកលោកទៅប្រគេនសម្ដេចព្រះមង្គលទេព្វាចារ្យព្រះនាម អៀម សង្ឃ-
នាយកវត្តបទុមវតី ឲ្យនៅសិក្សាព្រះត្រៃបិដក ។ លុះព្រះជន្ម ២១ ឆ្នាំ
សាមណេរ អ៊ុយ-ប៉ាង ឧបសម្បទជាភិក្ខុភាវៈនាមបញ្ញត្តិឆាយាហៅថា
ខេមកោ ។ តមកបានឡើងសមណស័ក្តិជាព្រះបាឡាត់អរិយមុនី ។
លុះបួសបាន ៧ ព្រះវស្សា បានសូមលាសម្ដេចព្រះមង្គលទេព្វាចារ្យជា
ឧបជ្ឈាយ៍ចេញទៅបំពេញវិជ្ជានៅក្រុងបាងកក អាស្រ័យនៅវត្តបវរ-
និវេសន៍ ក្នុងសំណាក់សម្ដេចព្រះមហាសមណៈ ខំព្យាយាមបំពេញវិជ្ជា
អស់រយៈ ៨ ព្រះវស្សាចេះដឹងសមគួរ ទើបវិលត្រឡប់មកប្រទេសកម្ពុជា
នៅអាស្រ័យក្នុងវត្តបទុមវតីដដែលវិញ ។ សម្ដេចព្រះមង្គល

ទេសាចារ្យព្រះនាម ស៊ុក បានតាំងសមណសក្តិលោកជាព្រះមហាឧត្តល; ខាងក្រោយមកបានតាំងសមណសក្តិជា ព្រះអមរកិរក្ខិត រាជាគណៈ ទីបក្តា ។ ព្រះថេរៈអង្គនេះមានគុណសម្បត្តិសមត្ថភាពបរិបូណ៌ បានចូលធ្វើជាក្រុមជំនុំព្រះត្រៃបិដក ដោយការស្ទាត់ជំនាញក្នុងមុខការរបស់លោក ទើបព្រះករុណា ព្រះរាជទានគ្រឿងឥស្សរិយយស (មេដៃយ៍) មណីសារភ័ណ្ឌ ហើយនិងតែងតាំងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ឲ្យសមតាមឋានៈរបស់លោក ។

*

* *

ម៉ោង ១៨ ថ្ងៃទី ៣ មិថុនា ១៩៥៤ ឯកឧត្តម ឆ្ងូ-ពៀង រដ្ឋមន្ត្រីក្រសួងធម្មការនិងឥស្សរជនព្រមទាំងនាហ៊ឺនធំ-តូច បានយកខ្ទឹមបន្ទ ទៅសូមខមាទោសចំពោះសពតាមទំនៀមទម្លាប់ រួច ឯ. ឧ. រដ្ឋមន្ត្រីក្រសួងធម្មការបានបូជាភ្លើងជាកិត្តិយស ។

ពិធីឈាបនកិច្ចសពនេះ បានបញ្ចប់នៅពេលម៉ោង ១៨ និង ២០ នាទី ។